ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



# ស្វែងរកការពិត

- ជីវិតម្ដាយ
- សិក្ខាសាលា «ការអប់រំអំពីសុខភាព» សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
- តើ «សាក្សីប្រវត្តិសាស្ត្រ» មានន័យធំធេងប៉ុណ្ណា?

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨៤ ខែសីហា ឆ្នាំ២០២៣

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៤ ខែសីហា ឆ្នាំ២០២៣



លោក ឆាំង យុ បួសនៅវត្តលង្កានៅថ្ងៃបុណ្យសពម្ដាយឈ្មោះ កែវ ណាន អាយុ ៩៥ឆ្នាំ ដែលទទួលមរណភាពកាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ

◆ ជីវិតម្ដាយ ........................................ ១
◆ សិក្ខាសាលា «ការអប់រំអំពីសុខភាព» ............ ៥

### ផ្នែកឯកសារ

◆ បេត រៀម ហៅ មាក ៖ លេខាស្រុកពាមរក៍ ..... ៨

### ផ្នែកប្រវត្តិសាស្រ្ត និងការស្រាវជ្រាវ

◆ សម្ដេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចន្ទថុល្ល ប្រគល់ទូបូរាណមួយ ជូន ................................ ១១
◆ តើ «សាក្សីប្រវត្តិសាស្រ្ត» មានន័យធំធេង ..... ១២
◆ មជ្ឈមណ្ឌលឯកសារកម្ពុជា ចែកជូនសៀវភៅ និងរៀបចំទុកដាក់ឯកសារក្នុងបណ្ណាល័យ ......... ១៤
◆ ប្រជាកសិករដាំបន្លែតាមដងទន្លេមេគង្គ នៅស្រុកស្រីសន្ធរ ទទួលសៀវភៅ «សាក្សី............ ១៦
◆ សហគមន៍នេសាទចាមនៅកោះសូទិន ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្រ្ត ៖ ............ ១៨
◆ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងជួបពិភាក្សា និងស្ដាប់រឿងរ៉ាវរបស់អ្នករស់រាន ... ២០
◆ គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ទទួលសៀវភៅ «សាក្សី.......... ២៥
◆ សិស្សានុសិស្សនៃអង្គការបណ្ដុះបណ្ដាលថ្នាក់មូលដ្ឋាន (OBT) ទស្សនកិច្ចសិក្សា........... ២៨
◆ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកោះសូទិន ទទួលសៀវភៅ «សាក្សី.......... ៣១
◆ សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ពាមជីកង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្រ្ត៖ ...... ៣៣
◆ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្រ្ត» កំណត់ហេតុ .. ៣៦
◆ ព្រះសង្ឃ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គ្រូបង្រៀន និងសិស្សានុសិស្ស នៅស្រុកស្អាង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្រ្ត» ....... ៣៩
◆ ឈូក អូន ៖ កម្មាភិបាលខ្មែរក្រហមទាញ ...... ៤១

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ សិស្សានុសិស្សវិទ្យាល័យនេតយ៉ង់ទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ................ ៤៣
◆ សិស្សវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ ចូលរួមទស្សនកិច្ចសិក្សាស្ដីអំពី «សន្តិភាព និង....... ៤៥
◆ សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ស្នួល ចូលរួមវេទិកាថ្នាក់រៀនស្ដីអំពីរបបកម្ពុជា ............ ៤៨
◆ វេទិកាថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅស្រុកអន្លង់... ៥០
◆ ក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពបឋម........ ៥២

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ អៀង សង ៖ ខ្ញុំបាត់បង់បងស្រីពីរនាក់ ........ ៥៧
◆ «ទួលពិឃាដ» (ត) ............................ ៥៩

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្រ្តី និងរដ្ឋមន្រ្តីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, សោម ប៊ុនថន, ដា៉រ៉ារដ្ឋ មេត្តា, ផាត ចាន់សុនិតា, ផេង ពង្សរ៉ាស៊ី, ព្រាំ ផល្លា, លី ដេវីត សាំង ចាន់ធូ, ឡុង ដានី, ផន វន្នី, សួត វិចិត្រ, មេក វិន, សុភ័ក្រ្ត ភាណា, គីម សុវណ្ណដានី, និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង រ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ជីវិតម្តាយ

ឆាំង យុ



លោក ឆាំង យុ បួសនៅវត្តលង្កានៅថ្ងៃបុណ្យសពម្តាយឈ្មោះ កែវ ណាន អាយុ ៩៥ឆ្នាំ ដែលទទួលមរណភាពកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។
(អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងជីវិតយើងម្នាក់ៗ តែងតែជួបប្រទះនូវហេតុការណ៍មួយចំនួន ដែលធ្វើឲ្យយើងនឹកគិតដល់គំនិតមួយ ក៏ដូចជាសំណួរមួយចំនួន ដែលហាក់បីដូចជាមានអានុភាពខ្លាំងណាស់នៅពេញមួយជីវិតរបស់យើង។ ដូចជាហេតុការណ៍នៃការចូលមន្ទីរពេទ្យដំណាក់កាលចុងក្រោយរបស់ម្តាយខ្ញុំនាពេលថ្មីៗនេះ គឺជាកាលៈទេសៈមួយដែរ ហើយហេតុការណ៍នេះមិនត្រឹមតែជំរុញឲ្យខ្ញុំនឹកគិតដល់ ជីវិតរបស់ម្តាយខ្ញុំតែប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឲ្យខ្ញុំបាននឹកគិតទៅដល់ការលះបង់របស់គាត់ចំពោះក្រុមគ្រួសារ កូនចៅ ក៏ដូចជាការលះបង់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ សម្រាប់ប្រជាជាតិកម្ពុជាទាំងមូល។

ម្តាយរបស់ខ្ញុំឈ្មោះ កែវ ណាន កើតនៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩២៨ ត្រូវនឹងឆ្នាំមស្សាញ់ នៅភូមិខ្មែរលើ ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ម្តាយរបស់ខ្ញុំ មានបងប្អូនប្រុសស្រីទាំងអស់៥នាក់គឺ កែវ អឿន, កែវ នី (ស្រី), កែវ អៃ, កែវ ឈឿន និងរូបគាត់។ ឪពុករបស់គាត់ឈ្មោះ កែវ អឿ និងម្តាយរបស់គាត់ឈ្មោះ សាគូ ណម។ ម្តាយរបស់ខ្ញុំ



លោក ឆាំង យុ ស្រោចទឹកលើអដ្ឋិធាតុរបស់ម្តាយ កែវ ណាន បន្ទាប់ពីបូជាដោយព្រះអគ្គិនៅមេរុ នៅវត្តលង្កា កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣។ (អ៊ួច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រៀបការជាមួយឪពុករបស់ខ្ញុំ ឈ្មោះ កែវ ទិន ដែលមានកំណើតនៅឆ្នាំ១៩២៣ ត្រូវនឹងឆ្នាំកុរ។ ឪពុករបស់ខ្ញុំ និងបងប្អូនទាំងអស់របស់ម្តាយខ្ញុំបានទទួលអនិច្ចកម្មអស់ហើយ។ ដូចទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀតដែរ គាត់មានកូនច្រើននាក់ ប៉ុន្តែកូនមួយចំនួនបានបាត់បង់ជីវិត អស់ទៅហើយ។ នៅលើលោកនេះ ប្រហែលជាគ្មានការឈឺចាប់ណា ស្មើនឹងការឈឺចាប់ ដែលកូនរបស់ខ្លួនត្រូវលាចាកលោកមុនឪពុកម្តាយនោះទេ ហើយរបបខ្មែរក្រហម គឺជារបបដែលបន្សល់ទុកនូវការឈឺចាប់ដ៏យូរអង្វែងមួយ ដែលធ្វើឲ្យកូនៗ ឪពុកម្តាយ និងគ្រួសាររបស់ពួកគាត់ជាច្រើនស្លាប់ទាំងគ្មានកំហុស។

ម្តាយរបស់ខ្ញុំ បានជួបរឿងដ៏គួរឲ្យរន្ធត់ច្រើនជាខ្លាំង ដោយគាត់ត្រូវប្រឈមមុខមើលកូនចំនួន៦នាក់ ក្នុងចំណោមកូន១០នាក់ទទួលមរណភាព។ កូនខ្លះ ស្លាប់នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដ៏ឃោរឃៅ។ ខ្ញុំគឺជាកូនពៅ ដែលជាកូនទី១០ ក្នុងគ្រួសារ ហើយម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា នៅពេលខ្ញុំកើតមក គាត់បានដាក់ឈ្មោះឲ្យខ្ញុំផ្សេងមួយទៀត ប៉ុន្តែដោយសារតែការភ័យខ្លាច និងជំនឿផ្សេងៗផងនោះ គាត់ក៏បានដាក់ឈ្មោះដូចសព្វថ្ងៃនេះមកឲ្យខ្ញុំ (គាត់ហៅខ្ញុំថា៖ អាយុ ដែលឈ្មោះពេញនោះគឺ ទីឃាយុកោ)។ ឈ្មោះរបស់ខ្ញុំដែលគាត់ដាក់ឲ្យនៅពេលដែលខ្ញុំកើត គឺសំដៅលើថ្ងៃដែលខ្ញុំកើត គឺថ្ងៃចន្ទ (គាត់ដាក់ឈ្មោះថា ច័ន្ទសុខ) ហើយគាត់ជឿថា ឈ្មោះនេះអាចជួយឲ្យខ្ញុំមានសំណាងល្អ អាចរស់រានមានជីវិតនៅក្នុងស្ថានភាពលំបាកដែលយើងរស់នៅក្នុងពេលនោះ។

កាលពីសម័យខ្មែរក្រហម ខ្ញុំនៅជាកូនក្មេងនៅឡើយ ហើយខ្ញុំមិនសូវដឹងច្រើនអំពីរបៀបរស់នៅនោះទេ។ ប៉ុន្តែខ្ញុំបានរៀនចេះអំពីរបៀបរស់បានយ៉ាងឆាប់រហ័ស ដោយសារតែខ្ញុំមិនអាចទ្រាំនឹងសេចក្តីស្រេកឃ្លាន ដែលទារុណកម្មមួយ ដ៏ធ្ងន់ធ្ងរមកលើរូបខ្ញុំ។





លោក ឆាំង យុ កូនប្រុសពៅ កែវ ណាន បួសនៅវត្តលង្កា ថ្ងៃដែលម្ដាយទទួលមរណភាពកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។ (អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុន្តែ ដូចទៅនឹងបងប្អូនប្រុសស្រីបង្កើតរបស់ខ្ញុំទាំងអស់ដែរ យើងតែងតែពឹងផ្អែកលើម្ដាយរបស់យើង ដើម្បីធ្វើជាអ្នកណែនាំ ពុះពារ និងជាអ្នកការពារ ថែទាំយើងដ៏រឹងមាំមួយ។ នៅពេលរំឭកអំពីអតីតកាលបែបនេះ គឺធ្វើឲ្យខ្ញុំមានចិត្តមិនស្ងប់ នៅពេលនឹកគិតដល់តួនាទីម្ដាយរបស់ខ្ញុំនៅក្នុងគ្រួសារ នៅក្នុងសម័យកាលដ៏លំបាកលំបិនបំផុតនោះ និងការទទួលស្គាល់តួនាទីរបស់គាត់ដែលកាន់តែតិចទៅៗ នៅបណ្ដាឆ្នាំក្រោយៗមកទៀត នៅក្នុងក្រុមគ្រួសាររបស់យើង។ ក្ដីរន្ធត់ដ៏ខ្លាំងប្រៀបបានទៅនឹងរបបខ្មែរក្រហមដែរនោះ ខ្ញុំគិតថា ស្មារតីរបស់ម្ដាយខ្ញុំ និងការផ្ដល់តម្លៃលើខ្លួនឯង គឺពិតជាអស្ចារ្យណាស់ក្នុងពេលនោះ ដោយសារតែយើងទាំងអស់គ្នាពឹងផ្អែកទៅលើគាត់ ដើម្បីអាចរស់បាន ហើយគាត់និងយើងទាំងអស់គ្នា ពិតជាទទួលស្គាល់ថានេះគឺជាការពិត។

មានការលើកឡើងផ្ទុយគ្នា យ៉ាងហោចណាស់ចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួន ដែលថាស្មារតីនៃការសម្រេចគោលបំណង និងតម្លៃគុណបំណាច់មួយចំនួនកើតឡើងដោយសារការឆ្លងកាត់សម័យខ្មែរក្រហម ហើយនៅពេលជីវិតយើងមានភាពល្អប្រសើរ សង្គមមានការរីកចម្រើនទៅមុខ ស្មារតីនៃការសម្រេចតម្លៃគុណបំណាច់នេះ ហាក់បីដូចជាមានការធ្លាក់ថយចុះ រហូតក្លាយជាការចងចាំមួយ ដែលត្រូវបានគេបំភ្លេចចោលសម្រាប់សង្គមកម្ពុជា បើទោះបីជាមិនមានការបំភ្លេចចោលទាំងស្រុងយ៉ាងណាក្ដី។

នៅក្រោយរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ខ្ញុំ និងខ្ញុំ នៅតែពឹងផ្អែកទៅលើជំហររឹងមាំរបស់ម្ដាយយើង ប៉ុន្តែនៅពេលដែលពេលវេលាចេះតែរំកិលទៅមុខ ហើយជីវិតក៏ចាប់ផ្ដើមត្រឡប់ទៅរកភាពនឹងនរ និងធម្មតាវិញម្ដងបន្តិចៗ យើងក៏បានចាប់ផ្ដើមលែងសូវពឹងផ្អែកទៅលើម្ដាយរបស់យើងតទៅទៀតដែរ។ ហើយនៅពេលដែលម្ដាយរបស់យើង មានវ័យកាន់តែចាស់ទៅៗ យើងមិនបានចងចាំអំពីស្មារតី ភាពរឹងមាំ ការដឹកនាំ ភាពនឹងនរ និងការថែទាំដូចដែលគាត់មានកាលពីនៅក្មេងទៀតឡើយ។

កូនៗរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមជំនាន់កូនរបស់ពួកគេនិងអ្នកជំនាន់ក្រោយៗ មិនត្រូវភ្លេចទេថា ឪពុកម្ដាយរបស់យើង ដែលបានរស់ក្នុងរបបខ្មែរក្រហមនោះ មិនត្រឹមតែដើរតួនាទីជាឪពុកម្ដាយ ជីដូនជីតា តាទួតយាយទួត របស់អ្នកជំនាន់ក្រោយនេះនោះទេ លើសពីនេះគាត់ទាំងអស់ក៏ជាវីរៈជនដែលមានគុណូបការៈចំពោះប្រទេសជាតិទៀតផង។

រហូតទាល់តែដល់ថ្ងៃនេះ ដែលស្ថានភាពសុខភាពម្ដាយរបស់ខ្ញុំ ចុះខ្សោយជាបន្តបន្ទាប់ ទើបខ្ញុំភ្ញាក់ខ្លួនថា ខ្ញុំនៅជំពាក់គុណបំណាច់គាត់ដ៏មហាធំធេង ហើយសង្គមខ្មែរនៅជំពាក់គុណូបការៈចំពោះវីរជនជំនាន់នោះយ៉ាងច្រើនលើសលុប ក្នុងការជួយរក្សាជីវិតគ្រួសាររបស់គាត់ទាំងអស់ ឲ្យរស់រាននៅក្នុងសម័យកាលដ៏យង់ឃ្នងមួយនេះ។



បងស្រីរបស់លោក ឆាំង យុ និងលោក ឆាំង យុ កូនប្រុស ពៅ កែវ ណាន បួសនៅវត្តលង្កានៅថ្ងៃដែលម្តាយ ទទួលមរណភាព នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។ (អ៊ួច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំសូមសម្តែងនូវការដឹងគុណជាអនេកចំពោះក្រុមវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិក ដែលបានជួយព្យាបាល និងថែទាំម្តាយរបស់ខ្ញុំ ជាពិសេសគឺលោកវេជ្ជបណ្ឌិតខ្មែរវ័យក្មេង ឆ ប៊ុនប៉ូល ឯកទេសផ្នែកថែទាំសួត និងផ្លូវដង្ហើម។ ហើយខ្ញុំក៏សូមដឹងគុណដល់វេជ្ជបណ្ឌិត កាំង គីមសាន និង លោកប្រធានវេជ្ជបណ្ឌិត បូរី សុថាណារិទ្ធ និងវេជ្ជបណ្ឌិត ភោគ សុវណ្ណ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីសំណាក់ប្រទេសបារាំង ក្នុងប្រព័ន្ធសុខាភិបាលសាធារណៈរបស់ប្រទេសកម្ពុជា ដែលការរួមចំណែកនេះ ពិតជាបានផ្តល់ជាជំនួយជាច្រើនដល់ប្រជាជនកម្ពុជាដែលមានតម្រូវការផ្នែកថែទាំវេជ្ជសាស្ត្រទំនើប ព្រមទាំងវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកវ័យក្មេងដែលបម្រើការងារនៅទីនោះ។ ការរួមចំណែកនេះ បានផ្តល់ឱកាសដល់យុវជនកម្ពុជាវ័យក្មេងក្នុងការសិក្សា អនុវត្ត និងសម្រួចជំនាញ និងឯកទេសរបស់ខ្លួននៅមណ្ឌលវេជ្ជសាស្ត្រដែលមានវិជ្ជាជីវៈខ្ពស់បែបនេះ។ គិលានុបដ្ឋាយិកាដែលក្លាយជាក្រុមគ្រួសារមួយរបស់ខ្ញុំគឺ លោកគ្រូពេទ្យ បញ្ញា លោកគ្រូពេទ្យ រ៉ាន់ លោកគ្រូពេទ្យ បូ និងលោកគ្រូពេទ្យ សា។ សរុបមក ម្តាយរបស់ខ្ញុំនឹងមិនអាចមានជីវិតរស់រានបានឡើយ ប្រសិនបើគ្មានការថែទាំពីសំណាក់វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកទាំងនោះ។

ជារួម ប្រទេសកម្ពុជា នឹងមិនអាចក្លាយជាប្រទេសដ៏រឹងមាំ និងមានភាពធន់រហូតមកដល់សព្វថ្ងៃនេះបានដែរ ប្រសិនបើគ្មានភាពរឹងមាំ ការលះបង់ និងវីរភាពរបស់មនុស្សចាស់ជំនាន់មុន ដែលបានឆ្លងកាត់របបខ្មែរក្រហម។ យើងពិតជាមានការដឹងគុណ សេចក្តីគោរព និងសូមផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ចំពោះគាត់គ្រប់ៗគ្នា។ នៅពេលដែលខ្ញុំសរសេរអត្ថបទនេះ ម្តាយរបស់ខ្ញុំ គឺនៅមានជីវិតនៅឡើយទេ ប៉ុន្តែខ្ញុំពិតជាមិនដឹងទេថា តើគាត់អាចនឹងនៅបន្តមានជីវិតរហូត ដល់ពេលដែលអត្ថបទនេះត្រូវបានចុះផ្សាយជាសាធារណៈដែរឬទេ។ ជីវិតរបស់គាត់គឺស្ថិតនៅក្នុងដៃទេវតាទៅហើយ ហើយខ្ញុំមិនមានអ្វីក្រៅពីការបួងសួងសូមឲ្យទេវតាថែរក្សាគាត់ជាប់ជានិច្ចតទៅ។ ម្តាយរបស់ខ្ញុំ ចាប់ផ្តើមមានជរាពាធនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ហើយទទួលមរណភាព នៅថ្ងៃសៅរ៍ ៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹង ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២និង៣៣នាទីភ្លឺ។

# សិក្ខាសាលា «ការអប់រំអំពីសុខភាព» សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*សោម ប៊ុនថន*



វាគ្មិនឆ្លើយតបទៅនឹងសំណួររបស់និស្សិតពេទ្យនៅក្នុងសិក្ខាសាលាស្តីអំពីសុខភាព ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅសណ្ឋាគារកាំបូឌីយ៉ាណា។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីខែមីនា ដល់ខែសីហា ឆ្នាំ២០២៣ គម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំសិក្ខាសាលាចំនួនបួនលើក ទាក់ទងនឹង «ការអប់រំអំពីសុខភាព» ជាមួយនិស្សិតវិទ្យាសាស្ត្រសុខាភិបាល និស្សិតពេទ្យមកពីសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា និងនិស្សិតអាហារូបករណ៍មុខវិជ្ជាសុខភាពសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួនជាង៣០០នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា និងការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងក្រុងភ្នំពេញ។



សិក្ខាសាលានេះ មានការចូលរួមពីវាគ្មិនសំខាន់ៗ ឯកឧត្តម សាន់ សាប អ៊ី រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានសមាគមនិស្សិតវិទ្យាសាស្ត្រសុខាភិបាលមូស្លីមកម្ពុជា, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាប្រធានគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរ









*និស្សិតពេទ្យចូលរួមសិក្ខាសាលាស្តីអំពីសុខភាពដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅសណ្ឋាគារកាំបូឌីយ៉ាណា។*
*( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )*

ក្រហម», លោក គ្រីស្តូហ្វ័រ ឌៀរីង អ្នកវាយតម្លៃគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, បណ្ឌិត លីហ្សា ប្រោន សាស្ត្រាចារ្យនៅសាកលវិទ្យាល័យស្តែនហ្វត និង ប៉ាឡូ អាតូ, វេជ្ជបណ្ឌិត ដេមី រ៉ែយ៍ ទីប្រឹក្សាគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម», វេជ្ជបណ្ឌិត គួច ម៉េងលី ប្រធានមូលនិធិ ម៉េងលី ជេ. គួច និងវេជ្ជបណ្ឌិត សុខ រ៉ាផុន មកពីមន្ទីរសម្រាកព្យាបាលឯកជន។

តាមរយៈគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» បានរកឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនកំពុងប្រឈមនឹងជំងឺ១០មុខគឺ ១) ជំងឺលើសឈាម ២) ជំងឺក្រពះពោះវៀន ៣) ជំងឺគ្រុនចាញ់ ៤) ជំងឺផ្លូវចិត្ត៖ ៥) ជំងឺបេះដូង ៦) ជំងឺឈឺសន្លាក់ ៧) ជំងឺហឺតរ៉ាំរ៉ៃ ៨) ជំងឺទឹកនោមផ្អែម ៩) ជំងឺរបេង និង ១០) ជំងឺភ្នែកត្រូវបានជ្រុក ដែលតម្រូវឲ្យមានការថែទាំ និងព្យាបាល។

របបខ្មែរក្រហមបានបន្សល់ទុកនូវភាពភ័យខ្លាចអស់ជាច្រើនឆ្នាំសម្រាប់ប្រជាជនកម្ពុជា ដូច្នេះរឿងរ៉ាវនៅក្នុងរបបនេះមិនគួរត្រូវបានបំភ្លេចចោលឡើយ ខណៈអ្នករស់រានមានជីវិតពីអំពើឃោរឃៅនេះកាន់តែមានវ័យចំណាស់ ពិសេសចាស់ៗនៅតាមទីជនបទដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជា។ ជាង៤០ឆ្នាំបានកន្លងផុតទៅហើយ ហើយឥឡូវនេះ សំឡេងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែត្រូវបានគេឮ។ ស្នាមរបួស និងការចងចាំមិនល្អរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានអូសបន្លាយពេលជាច្រើនឆ្នាំកន្លងមក និងមិនបានចាកចេញឆ្ងាយពីពួកគេឡើយ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមស្ទើរតែទាំងអស់សុទ្ធតែមានជីវភាពក្រីក្រ និងទទួលរងជំងឺដែលទាក់ទងនឹងវ័យចំណាស់ គួបផ្សំជាមួយការខ្វះខាតការយល់ដឹងអំពីការថែទាំសុខភាព និងកង្វះលទ្ធភាពទទួលបានការព្យាបាលនៅតាមគ្លីនិក និងមន្ទីរពេទ្យ។

គោលដៅសំខាន់មួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺការរក្សាការចងចាំពីសោកនាដកម្មពីអតីតកាល ដើម្បីឲ្យមនុស្សជំនាន់ក្រោយយល់ដឹងអំពីការពិតដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងកុំឲ្យប្រវត្តិសាស្ត្រនេះកើតឡើងម្តងទៀត ព្រមទាំងជួយថែរក្សាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យមានសុខភាពល្អ និងមានអាយុវែងដែលអាចប្រាប់រឿងរ៉ាវរបស់ខ្លួនដល់មនុស្សជំនាន់ក្រោយៗ។ ក្នុងន័យនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាដើរតួនាទីចម្បងក្នុងការផ្តល់សេវាថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើកិច្ចការនេះតាំងពីដើមឆ្នាំ២០១៦មកម្ល៉េះ ហើយកម្រងសំណួរត្រូវបានបង្កើតឡើងសម្រាប់ប្រមូលទិន្នន័យផ្ទាល់ខ្លួន និងបញ្ហាសុខភាពដោយផ្អែកលើរោគសញ្ញានៃជំងឺទូទៅ និងផលប៉ះពាល់ផ្លូវចិត្តលើសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ទាប់ពីរយៈពេលជាង១ឆ្នាំ ដែលស្មើរតែ៩៥ភាគរយ នៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១៧៥០នាក់ រស់នៅក្នុងខេត្តចំនួន៧ ត្រូវបានសម្ភាសន៍ ពិនិត្យសុខភាព និងព្យាបាលតាមការណែនាំពីវេជ្ជបណ្ឌិត។ ចម្លើយរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមត្រូវបានប្រមូល វាយតម្លៃ និងវិភាគ ហើយលទ្ធផលបានបង្ហាញដូចខាងក្រោម៖

- ៧៥ ភាគរយ គឺមានអាយុ៦០ ឆ្នាំ ដែលមានវ័យចាស់ និងចាស់ជរា
- ៩៥ ភាគរយ រស់នៅក្នុងស្ថានភាពក្រីក្រ និងរស់នៅជាមួយសាច់ញាតិ
- ៧០ ភាគរយ មិនមានសុខភាពល្អ
- ១០ ភាគរយ នៅតែទទួលរងពីសុបិនអាក្រក់ និងការធ្លាក់ទឹកចិត្តដែលទាក់ទងនឹងបទពិសោធន៍នៃអំពើឃោរឃៅពីរបបខ្មែរក្រហម
- ជំងឺទូទៅគឺជំងឺទឹកនោមផ្អែមប្រភេទទី២ លើសឈាម ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺបេះដូង ជំងឺរបេង ជំងឺ COPD ជំងឺមហារីក និងជំងឺគ្រុនចាញ់។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា និស្សិតនឹងចូលរួមជាមួយយើងក្នុងនាមជាអ្នកស្ម័គ្រចិត្តផ្នែកវេជ្ជសាស្ត្រ ដើម្បីជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជិត៥លាននាក់។ ទាំងនេះក៏ជាឱកាសដែលអ្នកស្ម័គ្រចិត្តបង្ហាញពីការយកចិត្តទុកដាក់ ការប្តេជ្ញាចិត្ត និងសមត្ថភាពនៃការធ្វើជាវេជ្ជបណ្ឌិតដ៏ល្អ។



និស្សិតពេទ្យចូលរួមសិក្ខាសាលាដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ទស្សនកិច្ចព្រះរាជបណ្ណាល័យហ្វូងម៉ែ។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ចេក រៀម ហៅ មាក ៖ លេខាស្រុកពាមរក៍ តំបន់២៤ ភូមិភាគបូព៌ា (២០៣)

**ជាវ៉រដ្ឋ មេត្តា**



កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ឆ្នាំ១៩៧២។ (មជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)

ខ្ញុំឈ្មោះ ចេត រៀម ហៅ មាក ភេទប្រុស អាយុ៣៦ឆ្នាំ នៅក្នុងឆ្នាំ១៩៧៦។ ខ្ញុំមានស្រុកកំណើតនៅភូមិគក ឃុំអង្គរទ្រេត ស្រុកព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំមានប្រពន្ធឈ្មោះ កុយ ជឿជន អាយុ២៨ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៦) មានស្រុកកំណើតនៅភូមិបាបោង ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ប្រពន្ធរបស់ខ្ញុំ ធ្វើការនៅមន្ទីរស្រុកពាមរក៍។ ខ្ញុំមានកូនស្រីម្នាក់ឈ្មោះ ឈា រស់នៅជាមួយប្រពន្ធរបស់ខ្ញុំ។ ឪពុករបស់ខ្ញុំឈ្មោះ ឡឹក និង ម្តាយឈ្មោះ មិញ ហើយអ្នកទាំងពីរបានស្លាប់តាំងពីឆ្នាំ១៩៧៥ នៅភូមិគក ឃុំអង្គទ្រេត។ ខ្ញុំមានបងប្អូនចំនួន៥នាក់ គឺ១) រូបខ្ញុំគឺជាបងគេបង្អស់ ២) ចេត អ៊ឹក ៣) ចេត សួន ៤) ចេត សឿន ៥) ចេត ឆាម ចូលធ្វើបដិវត្តន៍នៅអង្គភាពយោធាភូមិភាគបូព៌ា២០៣ នៅអាយុ២១ឆ្នាំ។

កាលពីតូចខ្ញុំឃ្វាលគោក្របី និងរស់នៅជាមួយឪពុកម្តាយ។ ពេលខ្ញុំអាយុ១០ឆ្នាំ ម្តាយខ្ញុំបានយកខ្ញុំឲ្យនៅវត្តអង្គរទ្រេត ហើយខ្ញុំរៀននៅទីនោះបានរយៈពេល៥ឆ្នាំ។ ពេលខ្ញុំអាយុ១៦ឆ្នាំ ឪពុកម្តាយរបស់ខ្ញុំបានឲ្យខ្ញុំបួសជានេន។ ខ្ញុំបានរៀនភាសាបាលីនៅវត្តលេ្វ ឃុំព្រែកសណ្តែក ស្រុកស៊ីធរកណ្តាល ដោយមានលោកគ្រូ សយ គឺជាគ្រូបាអាចារ្យ។ ពេលខ្ញុំអាយុ២០ឆ្នាំ បំពេញជាភិក្ខុ និងរៀនភាសាបាលី នៅវត្តមេបុណ្យ ស្ថិតនៅឃុំតាកោ ស្រុកព្រៃវែង

ខេត្តព្រៃវែង ដោយមានអាចារ្យ ស៊ឹម គឺជាគ្រូបាអាចារ្យ។ ក្រោយមកខ្ញុំបានទៅរៀននៅវត្តស៊ីងស្វូត ដែលមានទីតាំងនៅខាងកើតអ្នកលឿង និងក្រោយមកខ្ញុំមកនៅវត្តលង្កា។

ខ្ញុំចូលបដិវត្តន៍តាំងពីខែមករា ឆ្នាំ១៩៦៤ នៅវត្តលង្កា ក្រុងភ្នំពេញ។ កាលនោះ អ្នកនាំចូលឈ្មោះ សមមិត្ត មួន គឺជាអ្នកទទួលខុសត្រូវចលនាសង្ឃ។ តមកទៀតសមមិត្តមួន ឈឺស្លាប់នៅក្នុងឆ្នាំ១៩៧៤ នៅស្រុកបាភ្នំ។ ខ្ញុំចូលបក្សនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧០ ដោយមានអ្នកទទួលស្គាល់ឈ្មោះ សមមិត្តស្វូត។ ពិធីរៀបចំទទួលស្ថិតនៅភូមិព្រៃអង្គុញ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ កាលនោះ សមមិត្តស្វូត ទទួលជាអនុប្រធានកសិកម្មតំបន់២៤។

កាលពីខ្ញុំចូលបដិវត្តន៍ដំបូង ខ្ញុំទទួលភារកិច្ចដើរចលនាសង្ឃ និងបាចខិត្តប័ណ្ណ។ នៅក្នុងឆ្នាំ១៩៦៧ ខ្ញុំចេញពីវត្តលង្កា មកនៅវត្តស៊ីងស្វូតវិញ ក៏បានចលនាសង្ឃបានរយៈពេលចំនួន៣ខែ ក៏ចេញមកនៅវត្តកណ្តាល ស្ថិតនៅស្រុកកោះជ័យ (ស្រុកព្រះស្តេច) តំបន់២៤ ខេត្តព្រៃវែង។ ខ្ញុំគឺជាតំណាងសង្ឃនៅវត្តកណ្តាល។

នៅក្នុងឆ្នាំ១៩៧០ ខ្ញុំសឹកហើយបានចូលជាបក្ខជនពេញសិទ្ធិនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧០។ បន្ទាប់ពីខ្ញុំសឹក អង្គការចាត់តាំងខ្ញុំមកនៅស្រុកពាមរក៍ទទួលជាអនុប្រធានយោធាស្រុកពាមរក៍។

នៅឆ្នាំ១៩៧៣ ទទួលជាអនុលេខាស្រុកពាមរក៍ និងខែឧសភា ឆ្នាំ១៩៧៥ ទទួលជាលេខាស្រុកពាមរក៍។ ខ្ញុំស្គាល់មិត្តភក្តិជិតស្និទ្ធមួយចំនួនរួមមាន៖ មិត្តវ៉ន គឺជាសន្តិសុខស្រុកបាភ្នំ, មិត្តវិន គឺជាលេខាស្រុកត្របែក និង មិត្តវង់ គឺជាអនុលេខាស្រុកបាភ្នំ។

នៅក្នុងឆ្នាំ១៩៧៦ អង្គការចាប់ខ្ញុំមកសួរចម្លើយ ហើយមូលហេតុដែលអង្គការនាំខ្លួនខ្ញុំមកដោយសារខ្ញុំទទួលការចាត់តាំងក្បត់ពីឈ្មោះ ចាន់ ចក្រី គឺជាស្នងការនយោបាយច១ យោធា ប្រចាំក្រុងភ្នំពេញ។

ខ្ញុំសូមរៀបរាប់សកម្មភាពខ្សែចាត់តាំងក្បត់របស់ ចាន់ចក្រី ដូចតទៅ៖ នៅប្រហែលម៉ោង៧ថ្ងៃត្រង់យើងមានគ្នាចំនួន៨នាក់ គឺជាសង្ឃទាំងអស់៖ ១) ចាន់ចក្រី ២) សំអាត ៣) សារិន ៤) សារឿន ៥) វ៉ែន ៦) ថាច់ វ៉ែន ៧) សំអាន និង ៨) រូបខ្ញុំ។ នៅពេលចាត់តាំង ចាន់ចក្រី បានអប់រំខ្ញុំឲ្យរៀនសូត្រអំពីលក្ខណៈប្រជាជន យោសនាអប់រំប្រជាជនឲ្យស្របច្បាប់នឹងអង្គការបដិវត្តន៍។ ក្រោយមក ចាន់ចក្រី បានប្រគល់ភារកិច្ចមួយចំនួនឲ្យយើងរួមមាន៖ សំអាន ក្តាប់ប្រជាជននៅក្នុង ខេត្តកំពង់ស្ពឺ, សារិត ទទួលភារកិច្ចក្តាប់ប្រជាជននៅខេត្តតាកែវ, សារឿន ទទួលភារកិច្ចក្តាប់ប្រជាជននៅខេត្តស្ទឹងត្រែង, វ៉ែន ទទួលខុសត្រូវប្រជាជននៅខេត្តកំពង់ស្ពឺ, ថាច់ វ៉ែន ក្តាប់ប្រជាជននៅខេត្តកំពត, សំអាត ទទួលខុសត្រូវក្តាប់ប្រជាជនម្តុំរទេះឆេះ ខាងលិចពោធិ៍ចិនតុង ខេត្តកណ្តាល ហើយខ្ញុំទទួលខុសត្រូវគ្រប់គ្រងប្រជាជនខេត្តព្រៃវែង។

ចំណែកផែនការក្បត់ គឺចង់ឲ្យសង្គមកម្ពុជាប្រែក្លាយជាប្រទេសនាយទុននិយម ប្រឆាំងជាមួយអង្គការបដិវត្តន៍យូរអង្វែង, ប្រមូលកម្លាំងប្រជាជនឲ្យបានច្រើនដើម្បីវាយបដិវត្តន៍។ គម្រោងនៃការវាយបដិវត្តន៍គឺរយៈពេល៣ទៅ៥ឆ្នាំ គិតចាប់តាំងពីឆ្នាំ១៩៧០មកយ៉ាងយូរ នៅឆ្នាំ១៩៧៣ឬឆ្នាំ១៩៧៥។ ក្រោយមក ខ្ញុំបានចាត់តាំងកម្លាំងក្បត់ជាបន្តបន្ទាប់គឺ៖ ១) យ៉ាំង នៅឃុំប្រាសាទ ស្រុកពាមរក៍ ខេត្តព្រៃវែង ដែលខ្ញុំបានចាត់តាំងនៅក្នុងឆ្នាំ១៩៧៥ ឲ្យទទួលតួនាទីក្តាប់ប្រជាជននៅក្នុងឃុំប្រាសាទ ២) បូរ ភារកិច្ចនៅក្នុងបដិវត្តន៍ គឺជាអនុប្រធានឃុំពាមមានជ័យ ៣) សួរ ប្រធានឃុំពាមរក៍ ៤) សុន គឺជាប្រធានអភិបាលសហករណ៍ ភូមិបាក់ដោក ៥) យស់ ប្រធានឃុំព្រែករន្ទះ ស្រុកពាមរក៍ និងចាប់ពីឆ្នាំ១៩៧៥ ទទួលខុសត្រូវប្រជាជននៅក្នុងឃុំទាំងមូល ៦) ឆុន ប្រធានឃុំបាប្រាង ស្រុកពាមរក៍ ៧) យន មានភារកិច្ចលើការងារបដិវត្តន៍ និងជាប្រធានឃុំព្រែកណ្តៀង ហើយក្នុងឆ្នាំ១៩៧៥ ក្តាប់ប្រជាជនក្នុងឃុំព្រែកណ្តៀង ៨) ចៅ មានភារកិច្ចលើ

ការងាររបដិវត្តន៍ និងជាប្រធានឃុំបារាយណ៍ ហើយនៅក្នុងឆ្នាំ១៩៧៥ ទទួលខុសត្រូវប្រជាជននៅក្នុងភូមិបារាយណ៍កើត។

នៅខាងផ្នែកសេដ្ឋកិច្ច ខ្ញុំបានទាមទារថ្នាំពេទ្យខណៈពេលដែលកំពុងមានការខ្វះខាត ពិសេសទាមទារពីអង្គការ ក្នុងគោលបំណងយកថ្នាំពេទ្យមកបំផ្លាញ ចំណែកផ្នែកវប្បធម៌ ខ្ញុំបំផុសប្រជាជនឲ្យច្រៀងចម្រៀងពាលាអារ៉ាក់សែ ឲ្យនិយាយពាក្យបំអួងបំអាស ធ្វើយ៉ាងណាឲ្យពុករលួយ។

ខ្ញុំត្រូវបានឆ្មាំគុកសួរចម្លើយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៦ វេលាម៉ោង៧ ៖ ៣០ព្រឹក និងចប់ការសួរចម្លើយនៅម៉ោង១២ និង ៤៥នាទីយប់។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០០១៦៨។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ចេត វៀម ហៅ មាក ពិតប្រាកដយ៉ាងណានោះទេ។**



កងទ័ពខ្មែរក្រហមដែលបានផ្ដាច់ខ្លួនពីកម្ពុជាប្រជាធិបតេយ្យ ដើម្បីទៅចុះចូលជាមួយកងទ័ពវៀតណាមតាមបណ្ដោយព្រំដែនខ្មែរ-វៀតណាម ក្នុងឆ្នាំ១៩៧៨។ (មជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)

# សម្តេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចន្ទថុល្ល ប្រគល់ទូបូរាណមួយ ជូនបណ្ណាល័យសម្តេចម៉ែ

ផាត ចាន់សុនិតា





សម្តេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចន្ទថុល្ល ព្រះចៅអធិការវត្តលង្កា ព្រះកុសុមារាម នៅក្នុងពិធីបុណ្យសព កែវ ណាន់ ម្តាយរបស់លោក ឆាំង យុ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣។ (អ៊ួច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រគល់ទូបូរាណដែលសម្តេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចន្ទថុល្ល ព្រះចៅអធិការវត្តលង្កា ព្រះកុសុមារាម ប្រគល់ឲ្យលោក ឆាំង យុ ស្ថាបនិកព្រះរាជបណ្ណាល័យ ហ្លួងម៉ែ ដើម្បីជួសជុលយកមកប្រើប្រាស់តម្កល់ឯកសារនានា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្តេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចន្ទថុល្ល ព្រះចៅអធិការវត្តលង្កា ព្រះកុសុមារាម ប្រគល់ទូបូរាណមួយ មកឲ្យលោក ឆាំង យុ ស្ថាបនិកព្រះរាជបណ្ណាល័យ ហ្លួងម៉ែ ដើម្បីជួសជុលយកមកប្រើប្រាស់តម្កល់ឯកសារនានា ដែលប្រទានដោយសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ យើងឃើញមានស្លាកនៅសេសសល់ភ្ជាប់នឹងទូរឹយចំណាស់មួយនេះ ដែលបានផ្តល់ព័ត៌មានថាធ្វើឡើងនៅក្នុងឆ្នាំ១៩២៧ ត្រូវនឹងឆ្នាំថោះ ហើយព្រមទាំងមានដាក់ផងដែរថា ទូនេះមានតម្លៃ ១៦២រៀល កាលពីជំនាន់នោះ។

លោក ឆាំង យុ សូមសម្តែងនូវការដឹងគុណចំពោះការប្រគល់វត្ថុដែលមានតម្លៃជាប្រវត្តិសាស្ត្រនេះ ដែលសម្តេចចៅអធិការ និងមន្ត្រីសង្ឃវត្តលង្កា ទាំងអស់បានប្រគល់មកព្រះរាជបណ្ណាល័យ ហ្លួងម៉ែ ដើម្បីតម្កល់ឯកសារ និងរក្សាទុកឲ្យបានគង់វង្សល្អ។ អំណោយទាំងឡាយដែលមានតម្លៃចំពោះការងារវាមានសារសំខាន់មិនត្រឹមតែជាវត្ថុអំណោយដល់ព្រះរាជបណ្ណាល័យ ហ្លួងម៉ែប៉ុណ្ណោះទេ ប៉ុន្តែថែមទៀតផងនោះវាគឺជាអំណោយដល់សាធារណជន និងកូនចៅជំនាន់ក្រោយដែលអាចទទួលបាននូវចំណេះចេះដឹង រៀនសូត្រអំពីមរតកវប្បធម៌ដ៏មានតម្លៃរបស់ប្រទេសកម្ពុជា។

# តើ «សាក្សីប្រវត្តិសាស្ត្រ» មានន័យធំធេងប៉ុណ្ណា?

ផេង ពង្សរ៉ាស៊ី



កម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរនៅឃុំបុស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣ មានការរៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៨០ក្បាល នៅក្នុងបរិវេណវត្តញាណពោធិ៍ ស្ថិតក្នុងភូមិបុស្សីស្រុកក្រោម ឃុំបុស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដោយមានអ្នកចូលរួមចំនួន ៦០នាក់ ក្នុងនោះរួមមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៩ នាក់, គ្រូបង្រៀនមកពីវិទ្យាល័យបុស្សីស្រុកចំនួន២៣នាក់, សិស្សានុសិស្សចំនួន ២៧ នាក់ និងតំណាងសាលាស្រុកស្រីសន្ធរម្នាក់ៗ លោក អ៊ុំ ថារ៉ា ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកស្រីសន្ធរ បានថ្លែងមតិស្វាគមន៍ និងណែនាំក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដល់អ្នកចូលរួមបានស្គាល់ៗ លោកបានប្រាប់អំពីវត្ថុបំណងនៃកម្មវិធីចែកសៀវភៅ។ បន្ទាប់មក អ្នកចូលរួមទាំងអស់បានចំណាយពេលវេលាជាងកន្លះម៉ោង ដើម្បីអានសៀវភៅនេះ។ អ្នកចូលរួមមួយចំនួនបានបញ្ចេញមតិយោបល់របស់ខ្លួនចំពោះសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដូចខាងក្រោម៖

បន្ទាប់ពីអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

រួច លោក ម៉ៅ ស៊ី អាយុ៨០ឆ្នាំ មានប្រសាសន៍ថា «លោកគ្រូអ្នកគ្រូ និងក្មួយៗទាំងអស់! គាត់សុំសួរមួយថា តើសាក្សីប្រវត្តិសាស្ត្រមានន័យថាម៉េច? គាត់ក៏ជាសាក្សីប្រវត្តិសាស្ត្រមួយដែរ ព្រោះគាត់បានឆ្លងកាត់ផ្ទាល់ចំពោះប្រវត្តិសាស្ត្រដ៏ជូរចត់ក្នុងរបបខ្មែរក្រហម ហើយក៏ជាសាក្សីម្នាក់ៗ ពេលដែលគាត់ចូលព្រៃម៉ាគី ព្រោះចង់ឲ្យព្រះបាទ នរោត្តម សីហនុ មកគ្រប់គ្រងប្រទេសជាតិវិញៗ ប៉ុន្តែនៅក្នុងសៀវភៅនេះ សម្តេចម៉ែ ទ្រង់ជាសាក្សីមួយព្រះអង្គក្នុងពេលដែលទ្រង់យាងជាមួយព្រះបាទនរោត្តម សីហនុ មកកាន់ប្រទេសកម្ពុជា ដើម្បីជួបជាមួយប្រជាជន និងពង្រឹងកម្លាំងតស៊ូ ព្រមទាំងផ្តល់ទំនុកចិត្តខ្ពស់ដល់យើងដែលជាអ្នកគោរពស្រឡាញ់ព្រះអង្គ។ ដូច្នេះ សម្តេចម៉ែ ទ្រង់ជាអ្នកកត់ត្រារាល់ព្រឹត្តិការណ៍ សកម្មភាពរបស់ព្រះបាទនរោត្តម សីហនុ ក្នុងពេលដែលព្រះអង្គមានកិច្ចប្រជុំជំនួបពិភាក្សារាប់ព្រះរាជសកម្មភាពរបស់ព្រះអង្គក្នុងគ្រានោះគឺក្នុងឆ្នាំ១៩៧៣។ ខ្ញុំត្រេកអរណាស់ នៅពេលដែលខ្ញុំបានឃើញកំណត់ហេតុជាប្រវត្តិសាស្ត្រនេះ។ ខ្ញុំមិនបានកត់ត្រាប្រវត្តិសាស្ត្ររបស់ខ្ញុំទេ ហើយខ្ញុំជឿថា មនុស្សចាស់ៗជាច្រើននាក់ទៀត ក៏មិនបានកត់ត្រាប្រវត្តិខ្លួនឯងទុកសម្រាប់ក្មេងៗជំនាន់ក្រោយដែរ។ ដូច្នេះហើយ ខ្ញុំសូមថ្លែងអំណរគុណដល់សម្តេចម៉ែ ដែលលោកបានតាក់តែងសៀវភៅកំណត់ហេតុរបស់ទ្រង់ទុកសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយបានរៀនសូត្រ និងឈ្វេងយល់ពីសច្ចភាពប្រវត្តិសាស្ត្រកាលពីមុននៃប្រទេសរបស់យើង។ លោកគ្រូអ្នកគ្រូ និងចៅៗទាំងអស់គ្នាត្រូវចងចាំថា កំណត់ហេតុរបស់សម្តេចម៉ែនេះ គឺច្បាស់លាស់ណាស់ថា ទ្រង់យាងមកដើម្បីកូនចៅ ទ្រង់បានសុខ មិនក្លែងបន្លំទេ។ សូមចៅៗ យកចិត្តទុកដាក់អាន ហើយត្រូវដឹងអំពីប្រវត្តិសាស្ត្ររបស់យើងជាពិសេសព្រះរាជបេសកកម្មរបស់សម្តេចឪសម្តេចម៉ែ ដែលទ្រង់ទទួលរងការលំបាកច្រើនណាស់ ដើម្បីកូនចៅបានសុខៗ ប៉ុន្តែប៉ុល ពត ទេដែលជាអ្នកផាករេ។ ខ្ញុំសូមគោរពជូនពរសម្តេចម៉ែ សូមទ្រង់មានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា និងគង់ជាម្លប់ដល់កូនចៅ ទាំងអស់គ្នា។»

លោកគ្រូ ជន ដា អាយុ៥៦ឆ្នាំ លើកឡើងថា «ខ្ញុំឃើញព័ត៌មានផ្សាយអំពីការចែកចាយសៀវភៅសាក្សីប្រវត្តិសាស្ត្រ ខ្ញុំចង់បានសៀវភៅនេះណាស់ៗ ឥឡូវ ខ្ញុំទទួលបាន១ក្បាលដែរៗ ខ្ញុំកត់សម្គាល់ឃើញថា កំណត់ហេតុជាប្រវត្តិសាស្ត្ររបស់សម្តេចម៉ែ គឺមិនប៉ះពាល់ដល់ប្រទេសជិតខាងទេ។ ខ្ញុំនឹងអានសៀវភៅនេះឲ្យចប់នៅសប្តាហ៍ក្រោយ រួចហើយខ្ញុំបើកឲ្យមានការសួរដេញដោលអំពីសៀវភៅនេះ។ ខ្ញុំបង្រៀនមុខវិជ្ជាគណិតវិទ្យានៅវិទ្យាល័យឫស្សីស្រុក ប៉ុន្តែខ្ញុំនឹងឆ្លៀតពេលខ្លះៗដើម្បីនិយាយប្រាប់សិស្សខ្ញុំពីសៀវភៅកំណត់ហេតុនេះ ដើម្បីឲ្យសិស្សបានដឹងអំពីប្រវត្តិសាស្ត្ររបស់យើង ជាពិសេសដំណើរដ៏លំបាករបស់សម្តេចឪសម្តេចម៉ែ»។





កម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរនៅឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជា ចែកជូនសៀវភៅ និងរៀបចំទុកដាក់ឯកសារក្នុងបណ្ណាល័យ
## សម្រាប់បញ្ជាការដ្ឋានកងទ័ពជើងគោក និងយោធភូមិភាគពិសេស

ព្រុំ ផល្លា




ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដល់បញ្ជាការដ្ឋានកងទ័ពជើងគោក និងយោធភូមិភាគពិសេស នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។
( ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ដើម្បីគាំទ្រដល់ការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជូនបញ្ជាការដ្ឋានកងទ័ពជើងគោក និងយោធភូមិភាគពិសេសនូវសៀវភៅដែលត្រូវបានស្រាវជ្រាវដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួន ២២ក្បាល និងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាកំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរចំនួន ៣០០ក្បាល ដើម្បីចូលរួមក្នុងការស្រាវជ្រាវ និងដើម្បីចែកជូនដល់នាយទាហាននៅតាមអង្គភាពនានា។

កិច្ចពិភាក្សា និងការចែកជូនសៀវភៅធ្វើឡើងនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ នៅយោធភូមិភាគពិសេស ក្រោមអធិបតីភាពឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ មេបញ្ជាការរងកងទ័ពជើងគោកទទួលបន្ទុកការងារប្រវត្តិសាស្ត្រយោធាកងទ័ពជើងគោក ដែលដឹកនាំដោយឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ូ វណ្ណៈ មេបញ្ជាការរង នាយសេនាធិការយោធភូមិភាគ







ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាជួបប្រជុំជាមួយនាយទាហាននៅបញ្ជាការដ្ឋានកងទ័ពជើងគោក និងយោធភូមិភាគពិសេស នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។ (ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិសេស និងនាយទាហានមួយចំនួនទៀត និងវត្តមានបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានលោក ព្រាំ ផល្លា លោក សុខវណ្ណៈ និង លោក ទាវ សម្ផស្ស។

ជាមួយការទទួលរាក់ទាក់ពីនាយទាហាន ក៏មានការបង្ហាញពីបណ្ណាល័យមួយដែលទើបត្រូវបានបង្កើតឡើងដែលត្រូវការសៀវភៅប្រវត្តិសាស្ត្រសម្រាប់ជូននាយទាហានសិក្សា និងបន្ទាប់មកក៏មានការថ្លែងអំណរគុណពីឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលតែងតែសហការ និងផ្តល់ជាសៀវភៅ ព្រមទាំងឯកសារសម្រាប់គាំទ្រដល់ការងារក្នុងការបង្ក្រងប្រវត្តិសាស្ត្រយោធា។

នៅក្នុងឱកាសនោះដែរ ឯកឧត្តម ស៊ាម ហ៊ិ និង ឯកឧត្តម ប៉ូ វណ្ណៈ បានផ្តល់ជូននូវប្រវត្តិកសាងបណ្ណាល័យរបស់យោធភូមិភាគពិសេសនេះ និងបានរៀបរាប់ពីសកម្មភាពជាប្រវត្តិសាស្ត្ររបស់លោកក្នុងការចូលរួមក្នុងសង្គ្រាម និងការបញ្ចប់សង្គ្រាមតាមរយៈគោលនយោបាយ ឈ្នះ ឈ្នះ។ ជាការឆ្លើយតប លោក ព្រាំ ផល្លា បញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែគាំទ្រទៅដល់ការងារជាប្រវត្តិសាស្ត្រដែលខ្លួនបានអនុវត្តកន្លងមក និងនៅតែបន្តធ្វើទៅថ្ងៃមុខទៀត ដើម្បីការពារមិនឲ្យរបបប្រល័យពូជសាសន៍កើតមានជាថ្មី។

កម្មវិធីបានបញ្ចប់បន្ទាប់ពីការបង្ហាញពីចំណាប់អារម្មណ៍របស់ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ ទៅលើខ្លឹមសារ និងសារប្រយោជន៍របស់សៀវភៅសាក្សីប្រវត្តិសាស្ត្រដែលជាកំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។

# ប្រជាកសិករដាំបន្លែតាមដងទន្លេមេគង្គ នៅស្រុកស្រីសន្ធរ ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»

***លី ដេវីត***



នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដល់ប្រជាកសិករដាំបន្លែតាមដងទន្លេមេគង្គ សរុបចំនួន៤០នាក់ រស់នៅភូមិស្វាយលើ ឃុំស្វាយខ្សាច់ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ប្រជាកសិករដាំបន្លែតាមដងទន្លេមេគង្គ នៅភូមិស្វាយលើ ឃុំស្វាយខ្សាច់ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូនម៉ៃ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ក្នុងដំណើរឆ្ពោះទៅកាន់ទីតាំងចម្ការបន្លែតាមដងទន្លេមេគង្គ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលជាខសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំដោយលោក ស៊ាង ចិន្តា, លី ដេវីត និងសាំង ចាន់ធូ ចុះទៅជួបជាមួយប្រជាកសិករដែលកំពុងដាំដុះម្រះ ខាត់ណា ត្រកួន ស្ពៃតឿ ស្ពៃផ្កា សណ្តែកគួរ និងននោង នៅសហគមន៍កសិកម្មស្វាយខ្សាច់ ស្រុកស្រីសន្ធរ សរុបចំនួន៤០នាក់ និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដល់ប្រជាកសិករទាំងអស់នោះ។

នៅឱកាសចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម លើកឡើងអំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រសម្រាប់ការសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រចេញពីព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ មកកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣។

បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ប្រជាកសិករដាំបន្លែតាមដងទន្លេមេគង្គនៅសហគមន៍កសិកម្មស្វាយខ្សាច់ ស្រុកស្រីសន្ធរ បង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

ខ្ញុំឈ្មោះ ស៊ិន ស៊ាងឡេ អាយុ៥៣ឆ្នាំ គឺជាកសិករដាំបន្លែរស់នៅភូមិស្វាយលើ ឃុំស្វាយខ្សាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំពិតជាត្រេកអរយ៉ាងខ្លាំងដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាស្នាព្រះហស្តផ្ទាល់របស់ហ្លួងម៉ែ។ ខ្ញុំអាចបើកអាន ឬមើលរូបព្រះឆាយាល័ក្ខណ៍នៅក្នុងសៀវភៅនេះ បន្ទាប់ពីទំនេរដាំដុះបន្លែ។ ជាចុងក្រោយ ខ្ញុំសូមថ្វាយព្រះពរ ហ្លួងម៉ែ មានព្រះរាជសុខភាពល្អបរិបូរណ៍ និងព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់សម្រាប់ប្រជារាស្ត្រខ្មែរ។

ខ្ញុំឈ្មោះ ហ៊ាង តាំង ឡួត អាយុ៤៥ឆ្នាំ គឺជាកសិករដាំម្រះ នៅភូមិស្វាយលើ ឃុំស្វាយខ្សាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានអារម្មណ៍ត្រេកអរបន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»។ សៀវភៅនេះ គឺជាព្រះរាជនិពន្ធរបស់ហ្លួងម៉ែផ្ទាល់ ហើយខ្ញុំយល់ថាពិតជាល្អខ្លាំងណាស់។ ខ្ញុំនឹងយកសៀវភៅនេះទៅចែករំលែកដល់កូនៗរបស់ខ្ញុំដែលកំពុងរៀននៅអនុវិទ្យាល័យ ដើម្បីអាន និងយល់ដឹងពីប្រវត្តិសាស្ត្រ។ ជាចុងក្រោយ ខ្ញុំសូមអរគុណព្រះរាជបណ្ណាល័យ ហ្លួងម៉ែ និងអំណរព្រះគុណហ្លួងម៉ែ ដែលបានចែកសៀវភៅដែលជាព្រះរាជានិពន្ធផ្ទាល់ព្រះហស្តដល់កូនចៅអានគ្រប់ៗគ្នាដើម្បីដឹងពីប្រវត្តិសាស្ត្រ។

ខ្ញុំឈ្មោះ ណៃ សឿន អាយុ៥៧ឆ្នាំ គឺជាកសិករដាំស្ពៃក្ដោប នៅភូមិស្វាយលើ ឃុំស្វាយខ្សាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំសប្បាយចិត្តពេលដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាស្នាព្រះហស្តរបស់ហ្លួងម៉ែ។ ខ្ញុំនឹងមើលសៀវភៅនេះនៅពេលទំនេរពីការដាំស្ពៃក្ដោប។







នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ក្រុមការងាររមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដល់ប្រជាកសិករដាំបន្លែតាមដងទន្លេមេគង្គ សរុបចំនួន៤០នាក់ រស់នៅភូមិស្វាយលើ ឃុំស្វាយខ្សាច់ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សហគមន៍នេសាទចាមនៅកោះសូទិន ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ៖

## កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»

**សាំង ចាន់ធូ**



នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដល់ប្រជាជននៅសហគមន៍ចាមសរុបចំនួន៤០នាក់ រស់នៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជានេសាទដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅសហគមន៍ចាមក្នុងភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម សរុបមានចំនួន៤០នាក់ ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» បោះពុម្ពផ្សាយដោយបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

នៅរសៀលថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយលោក ស៊ាង ចិន្តា, លី ដេវីត និង សាំង ចាន់ធូ ចុះទៅជួបប្រជានេសាទដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជន-យុវនារី នៅសហគមន៍ចាមនៅឃុំកោះសូទិន និងបានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដល់អ្នកទាំងនោះ។ ក្នុងអំឡុងពេលចែកសៀវភៅ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បញ្ជាក់អំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រសម្រាប់ការសិក្សាឈ្វេងយល់ចេញពីព្រះរាជកំណត់ហេតុរបស់ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ





នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ក្រុមការងាររមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ«សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់ប្រជាជននៅសហគមន៍ចាមសរុបចំនួន៤០នាក់ រស់នៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)




ក្នុងព្រះរាជដំណើរអមសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ មកទស្សនកិច្ចតំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣។

បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» ប្រជានេសាទ និងយុវជន-យុវនារី នៅសហគមន៍ចាមកោះសូទិនបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ ហ៊ីម ស្រីវ៉ាស់ អាយុ១៧ឆ្នាំ ប្រកបមុខរបរលក់ត្រី រស់នៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានអារម្មណ៍រំភើបដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាស្នាព្រះហស្តរបស់ហ្លួងម៉ែ។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាឯកសារប្រវត្តិសាស្ត្រដ៏មានតម្លៃសម្រាប់យុវជនយុវនារីជំនាន់ក្រោយ។ ខ្ញុំនឹងយកអ្វីដែលខ្ញុំដឹងពីសៀវភៅនេះទៅចែករំលែកជាមួយក្រុមគ្រួសារ និងមិត្តភ័ក្តិផ្សេងទៀតក្នុងសហគមន៍។

ខ្ញុំឈ្មោះ ហូសាន់ តារីត អាយុ២៧ឆ្នាំ គឺជាអ្នកនេសាទ និងជាគ្រូបង្រៀនស្ម័គ្រចិត្តនៅសហគមន៍ស្ថិតនៅក្នុងភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរីករាយយ៉ាងខ្លាំងពីព្រោះខ្ញុំអាចអានសៀវភៅប្រវត្តិសាស្ត្រនេះ បន្ទាប់ពីការនេសាទ និងការបង្រៀន។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺពិតជាមានតម្លៃខ្លាំងណាស់សម្រាប់ខ្ញុំ។ ខ្ញុំនឹងយកព័ត៌មានដែលខ្ញុំដឹងចេញពីសៀវភៅនេះទៅចែករំលែកទៅកាន់យុវជនជំនាន់ក្រោយ។ ខ្ញុំសូមថ្វាយព្រះពរ ហ្លួងម៉ែ មានព្រះរាជសុខភាពល្អ និងព្រះជន្មាយុយឺនយូរ។

ខ្ញុំឈ្មោះ សេន ប៉ាទ្រី អាយុ២៧ឆ្នាំ ប្រកបមុខរបរនេសាទត្រី និងលក់ត្រី រស់នៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានអារម្មណ៍រំភើប នៅពេលដែលបានទទួលសៀវភៅដែលជាស្នាព្រះហស្តរបស់សម្តេចម៉ែដើម្បីអាន។ ខ្ញុំសូមសំណូមពរទៅកាន់ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តចែកសៀវភៅទៅកាន់បងប្អូននៅសហគមន៍ឲ្យបានគ្រប់គ្នាដើម្បីយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរ។ ជាចុងក្រោយ ខ្ញុំសូមថ្វាយព្រះពរជូន ហ្លួងម៉ែ មានព្រះរាជសុខភាពល្អ និងព្រះជន្មាយុយឺនយូរ។

# ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងជួបពិភាក្សា និងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការនៅភូមិស្ទឹងថ្មី

ឡុង ដានី



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងជួបពិភាក្សា និងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង រួមមាន៖ ឡុង ដានី, ធី គឹមហុង និង ឡុង អូន បានធ្វើដំណើរទៅផ្ទះប្រធានភូមិស្ទឹងថ្មី ឈ្មោះ ប៊ុន ស្រីពៅ និងជួបពិភាក្សាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាជនពិការរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ចំនួន១៧ នាក់ ក្នុងចំណោមនោះមានស្រីចំនួន២ នាក់។

ជាកិច្ចចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានធ្វើការណែនាំខ្លួន និងក្រុមការងារជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់។ បន្ទាប់មក លោក ឡុង ដានី បានជម្រាបជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថា មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានចាប់ផ្តើមដំណើរការនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ដោយមានទីតាំងស្ថិតនៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ

ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ការបើកដំណើការមជ្ឈមណ្ឌលផ្សះផ្សាវាលវែងមានគោលបំណងដូចខាងក្រោម ៖

១) បង្ហាញអំពីប្រវត្តិសាស្ត្រ និងសង្គ្រាមនៅប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៩០។

២) ពង្រឹងការកសាងសន្តិភាព និងទប់ស្កាត់ជម្លោះ តាមរយៈកម្មវិធីអប់រំជាឱកាសសម្រាប់យុវជនរស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែក និងបង្រៀនក្មេងជំនាន់ក្រោយ នូវបទពិសោធន៍របស់ពួកគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។

៤) ប្រមែប្រមូលចងក្រងទីតាំងប្រវត្តិសាស្ត្រយោធា និងរឿងរ៉ាវបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

៥) ជួយសម្របសម្រួលលើគម្រោងលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាកិច្ចបន្ទាប់លោក ឡុង ដានី បានផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាជនពិការចែករំលែកបទពិសោធន៍អំពីសង្គ្រាម អំពីការលំបាកក្នុងការរស់នៅបច្ចុប្បន្ន និងសំណូមពរដូចខាងក្រោម៖

## ចាន់ ដាន

ចាន់ ដាន ភេទប្រុស អាយុ៧៧ឆ្នាំ រៀបរាប់ថា ខ្ញុំមានស្រុកកំណើតនៅភូមិនីពេច ឃុំនីពេច ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ម្តាយខ្ញុំឈ្មោះ អ៊ុច សៀក និងឪពុកឈ្មោះ ចាន់ ចក់។ ខ្ញុំគឺជាកូនទី១ ក្នុងចំណោមបងប្អូនចំនួន៦នាក់ ប្រុស ៥នាក់ និងស្រី១នាក់។ កាលពីកុមារ ខ្ញុំបួសរៀននៅវត្តនីពេច រហូតដល់ឆ្នាំ១៩៧០ ក៏បានសឹកវិញព្រោះដឹងថាមានទាហាន លន់ នល់ ដើរចាប់អ្នកភូមិ និងព្រះសង្ឃតាមវត្តដើម្បីធ្វើទាហាន។ បន្ទាប់ពីទទួលដំណឹងនេះ ខ្ញុំនិងព្រះសង្ឃផ្សេងៗទៀតបានភៀសខ្លួនចូលក្នុងព្រៃនៅក្នុងភូមិនីពេច ហៅ ថា ទន្លេម្រេច។ ពេលនោះមានព្រះសង្ឃតាមវត្តផ្សេងទៀត ក៏ត្រូវទាហាន លន់ នល់ ចាប់យកទៅធ្វើទាហានខាងរដ្ឋាភិបាលស្រោចស្រង់ជាតិដែរ។ ក្រុមព្រះសង្ឃប្រហែល១០០អង្គ រួមទាំងខ្ញុំបានរត់ចូលព្រៃហៅថាទន្លេម្រេច។ បន្ទាប់មក បានសឹកចូលក្នុងអង្គភាពដែលមានអ្នកដឹកនាំឈ្មោះ សំ អឿន។ ខ្ញុំរៀនផ្នែកនយោបាយអស់រយៈពេល៦ខែ បន្ទាប់មកខ្មែរក្រហមបែងចែកមកនៅកងវរសេនាតូចលេខ៣១០។ ខ្ញុំបានមកឈរជើង និងវាយនៅសមរភូមិចេនឡាទី១ ខាងស្ទឹងជីនិត។ ចំណែក សមរភូមិចេនឡាទី២ វាយនៅកំពង់ថ្ម ក្នុងឆ្នាំ១៩៧២។ បន្ទាប់ពីបញ្ចប់សង្គ្រាមនៅសមរភូមិចេនឡាទី១ និងសរភូមិចេនឡាទី២ អង្គភាពរបស់ខ្ញុំបានផ្លាស់មកឈរជើងនៅស្គន់។ មកដល់



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងជួបពិភាក្សានិងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្នាំ១៩៧៨ អង្គភាពខ្ញុំវាយចូលទីក្រុងភ្នំពេញ។

ពេលចូលដល់ភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឈរជើងនៅផ្សារថ្មី និងទួលគោក។ បន្ទាប់មកក៏មកនៅជ្រោយចង្វារ និងបានចូលរួមជម្លៀសប្រជាជនចេញពីភ្នំពេញ។ មេបញ្ជាការចាត់តាំងឲ្យខ្ញុំដើរប្រមូលរបស់របរសម្ភាររបស់ប្រជាជនរយៈពេលមួយឆ្នាំ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានដកខ្ញុំរួមទាំងសមាជិកនៅអង្គភាពប្រហែលជា ៣០០នាក់ ទៅខេត្តកំពង់ឆ្នាំង ដើម្បីយាមការពារជនជាតិចិនមកធ្វើព្រលានយន្តហោះ។

នៅឆ្នាំ១៩៧៩ ខ្ញុំបានចេញពីកំពង់ឆ្នាំងមករស់នៅតាមព្រំដែនកម្ពុជា-ថៃ។ ខ្ញុំបានរៀបគ្រួសារក្នុងឆ្នាំ១៩៨៥។ ក្រោយមក ខ្ញុំដាក់ទ័ពនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៨៥។ ខ្ញុំបានមករស់នៅភូមិស្ទឹងថ្មី ស្រុកវាលវែងនេះតាំងពីឆ្នាំ១៩៩៣ រហូតដល់បច្ចុប្បន្ន។

ជាចុងក្រោយ ខ្ញុំសូមស្នើសុំឲ្យមានការយកចិត្តទុកដាក់ដល់ជនពិការ និងបង្កើតមូលនិធិសម្រាប់ជនពិការ។ ខ្ញុំស្នើដល់មណ្ឌលសុខភាពគួរមានថ្នាំគ្រប់គ្រាន់សម្រាប់ជនពិការ ព្រោះបច្ចុប្បន្នមណ្ឌលសុខភាពយើងមិនទាន់មានថ្នាំដែលអាចព្យាបាលបានគ្រប់គ្រាន់ គឺនៅមានការខ្វះខាតច្រើន។

## ចិន បឿន

ចិន បឿន ភេទប្រុស អាយុ៦៩ឆ្នាំ មានមុខរបរធ្វើស្រែចម្ការ បានរៀបរាប់អំពីប្រវត្តិរបស់ខ្លួនថា ខ្ញុំមានស្រុកកំណើតនៅភូមិគោកច័ន្ទ ឃុំល្វាក្រាំង ស្រុកវ៉ារិន ខេត្តសៀមរាប។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្ទឹងថ្មី ចំណុចស្រែតាំយ៉ៃ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ឪពុកខ្ញុំឈ្មោះ ជឿន ចិន និងម្តាយឈ្មោះ ពេក ព្រិន។ ខ្ញុំគឺជាកូនទី៦ក្នុងចំណោមបងប្អូនចំនួន៧ នាក់ គឺប្រុស៤ និងស្រី៣នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ ម៉ែ សារ៉ុំ អាយុ៥១ឆ្នាំ។ ខ្ញុំបានលែងលះគ្នាតាំងពីខ្ញុំមានកូន២នាក់គឺប្រុសទាំង២។

កាលនៅកុមារ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៧ចាស់។ ខ្ញុំចូលរៀននៅសាលារៀនភូមិគោកច័ន្ទ ក្នុងឆ្នាំ១៩៦៣។ គ្រូរបស់ខ្ញុំឈ្មោះ សាមឿន។ ចូលដល់ឆ្នាំ១៩៧០ ខ្ញុំចូលជាយុវជនភូមិ ខ្ញុំបានឃើញទាហាន



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងជួបពិភាក្សា និងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងជួបពិភាក្សា និងស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចុះមកតាមភូមិ និងបាននិយាយថា វៀតណាមកំពុងវាយនៅអន្លង់វែង បន្ទាប់មកខ្ញុំបានឃើញខ្មែរក្រហមចូលភូមិខ្ញុំពីរទៅបីនាក់ ដើម្បីមកធ្វើការឃោសនានយោបាយឲ្យប្រជាជនចូលរួមជាមួយគេ ប៉ុន្តែមិនបានបង្ខំទេ។ ខ្មែរក្រហមចូលទៅក្នុងភូមិពេលអវត្តមានកងទ័ពវៀតណាម។ នៅពេលកងទ័ពវៀតណាមចូលមកភូមិវិញ ខ្មែរក្រហមក៏ដកកម្លាំងចេញទៅវិញដែរ។ ក្រោយមក ខ្មែរក្រហមបានប្រមូលកម្លាំងប្រឆាំងវៀតណាម ហើយខ្ញុំក៏បានចូលរួមជាមួយខ្មែរក្រហមដែរ។ ខ្មែរក្រហមបានប្រមូលយុវជននៅក្នុងភូមិ ហើយបង្កើតទៅជាកងការពារភូមិ ដោយមានអង្រឹង កាំភ្លើង និងគ្រាប់បែកនៅជាប់ខ្លួន។ បន្ទាប់មកលោកគ្រូ សំអឿន ដែលបានបង្រៀនខ្ញុំ បានយកខ្ញុំចូលក្នុងកងសិល្បៈអស់រយៈពេល៣ទៅ៤ខែ។ ក្រោយមកខ្ញុំបានចូលកងទ័ពរំដោះ ហើយត្រូវបានខ្មែរក្រហមបញ្ជូនទៅរៀននយោបាយ។ ខ្ញុំត្រូវបានចាត់តាំងមកវាយ ទាហាន លន់ នល់ នៅខុដុង្គ។

នៅឆ្នាំ១៩៧៥ ខ្ញុំបានទៅដល់ភ្នំពេញនិងចូលរួមជម្លៀសប្រជាជនចេញពីក្រុង។ បន្ទាប់មក ខ្មែរក្រហមបញ្ជូនខ្ញុំមកធ្វើស្រែនៅកប់ស្រូវ។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យទៅរៀនបើកយន្តហោះនៅប្រទេសចិន។ មុនចេញដំណើរខ្មែរក្រហមបានពិនិត្យសុខភាពខ្ញុំ ហើយនៅឆ្នាំ១៩៧៧ ទើបខ្ញុំបានចូលរៀនបើកយន្តហោះ។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានត្រឡប់មកកម្ពុជាវិញ ពេលកងទ័ពវៀតណាមចូលមក។ ខ្ញុំបានរត់មកបាត់ដំបង និងបន្តទៅដល់សំឡូត ដោយហូបតែដំឡូង។ ជើងរបស់ខ្ញុំពិការនៅឆ្នាំ១៩៨៨ ដោយសាជាន់មីន។

នៅឆ្នាំ១៩៩៦ ខ្ញុំបានផ្លាស់មករស់នៅស្រុកវាលវែងរហូតដល់សព្វថ្ងៃ។

ជាចុងក្រោយ ខ្ញុំស្នើសុំជាអង្ករប្រចាំខែ ទោះបីតិចឬច្រើនសម្រាប់ជនពិការ និងថវិកាមួយចំនួនពេលចាំបាច់ត្រូវការទិញថ្នាំពេទ្យ និងព្យាបាលជំងឺ។

## ដាង ទឹម

ដាង ទឹម អាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅភូមិអន្លង់ភេ ឃុំអន្លង់វែង ស្រុកថា ឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង មានប្រសាសន៍ថា បច្ចុប្បន្នខ្ញុំរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំគឺជាកូនទី១ក្នុងចំណោមបងប្អូនចំនួន៥នាក់ គឺស្រី១នាក់ និងប្រុស៤នាក់ ។ ឪពុកខ្ញុំឈ្មោះ ហឹង ចំណែកម្តាយខ្ញុំឈ្មោះ ដាន់ មី។ អ្នកទាំងពីរបានទទួលមរណភាពអស់ហើយ។ ខ្ញុំមានប្រពន្ធឈ្មោះ ណាន់ នឿនបានទទួលមរណភាពកាលពីឆ្នាំ២០០៧។

កាលពីកុមារខ្ញុំបានចូលរៀនត្រឹមថ្នាក់ទី១០ចាស់។ នៅឆ្នាំ១៩៧០ ខ្ញុំរស់នៅជាមួយឪពុកម្តាយជួយឃ្វាលគោ និងធ្វើស្រែចម្ការ។ មកដល់ឆ្នាំ១៩៧១ ខ្ញុំបានចូលបម្រើការងារអង្គការ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបញ្ជូនខ្ញុំមកភ្នំពេញធ្វើការនៅក្រសួង៨៧០ ផ្នែកខាងយោធា។ ខ្ញុំមានតួនាទីជាកងការពារ និងយាមស្ថានទូតអេហ្ស៊ីបស្ថិតនៅម្តុំទួលគោក។ ប្រធានក្រុមរបស់ខ្ញុំឈ្មោះ តាកែន។ បន្ទាប់មកខ្ញុំបានទៅខាងកាំបូឌីយ៉ាណាវិញ ដែលខ្មែរក្រហមហៅថា កន្លែងអប់រំនយោបាយ។ ខ្ញុំយាមនៅទីនោះទាំងយប់ទាំងថ្ងៃរយៈពេល២ឆ្នាំ។

នៅឆ្នាំ១៩៧៩ ក្រុមរបស់ខ្ញុំបានដឹកមន្ត្រីស្ថានទូតតាមរថយន្តក្រុងយកទៅព្រំដែនកម្ពុជាថៃ ដើម្បីឲ្យមន្ត្រីស្ថានទូតទាំងនោះត្រឡប់ទៅប្រទេសរបស់ពួកគាត់វិញ។ ខ្ញុំដឹកបានពីរលើកគឺមន្ត្រីទូតចិន និងអាហ្វ្រិក។ បន្ទាប់មក ខ្ញុំបានដើរតាមព្រំដែនពីប៉ោយប៉ែតកាត់តាមប៉ៃលិនរហូតមកដល់សំឡូត។ ខ្ញុំបានចេញពីសំឡូតមកនៅ ខាង ច១ ច២ វិញ ជាប់នឹងព្រំដែនថៃ។ ច២ គឺជាកន្លែងទុកដាក់អីវ៉ាន់។ ខ្ញុំរស់នៅទីនោះប្រហែល៤ទៅ៥ឆ្នាំ រហូតដល់វៀតណាមវាយលុកខ្លាំង ទើបក្រុមរបស់ខ្ញុំវាយបកវិញតាមច្រកថ្មដា សំឡូត និងច្រក៥០៥។ អំឡុងពេលនោះ ខ្ញុំពិការជើងដោយសារជាន់មីននៅខែមករា ឆ្នាំ១៩៨៥ ដែលជាមីនរបស់កងទ័ពវៀតណាមនៅថ្មដា ត្រង់ចំណុចស្ទឹងមេទឹក។ ខ្ញុំបានទៅព្យាបាលនៅពេទ្យកងទ័ពជិតព្រំដែនរយៈពេល៧ខែ។ ចាប់តាំងពីពេលនោះខ្ញុំលែងទទួលការងារកងទ័ពទៀតហើយ។ ក្រោយមក ខ្ញុំបានមករស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ រហូតដល់ពេលបច្ចុប្បន្ន។

ចុងក្រោយ ខ្ញុំស្នើសុំឲ្យរដ្ឋជួយ ធ្វើអណ្តូងទឹកមួយ ដើម្បីកាត់បន្ថយការចំណាយក្នុងការទិញទឹកជាប្រចាំថ្ងៃ។

## ជា ភាន

ជា ភាន ភេទប្រុស អាយុ៦៦ឆ្នាំ មានប្រពន្ធឈ្មោះ ហ ភឿន មានអាយុ៥៨។ ជា ភាន មានប្រសាសន៍ថា ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកតាកែ ឃុំល្វេ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ឪពុកខ្ញុំឈ្មោះ ជា ភឿន និងម្តាយឈ្មោះ សុក សំ។ ខ្ញុំគឺជាកូនទី៤ ក្នុងចំណោមបងប្អូនចំនួន៥នាក់គឺ ប្រុស៣នាក់ ស្រី២នាក់។

កាលនៅកុមារ ខ្ញុំបានរៀននៅសាលាអូរាំងឪបានប្រហែលជាង២ខែ ក៏ដូរទៅរៀនសាលាពាមជាំង និងសាលាតាហៀវ។ នៅឆ្នាំ១៩៧០ ខ្ញុំបានត្រឡប់មករស់នៅក្នុងភូមិ និងធ្វើស្រែចម្ការរហូតដល់ឆ្នាំ១៩៧៥។ ក្រោយមក ខ្ញុំបានបែកគ្រួសារមករស់នៅភ្នំពេញដោយធ្វើជាកម្មករអគ្គិសនីរយៈពេលមួយឆ្នាំ។ នៅពេលនោះ ប្រសិនបើនរណាម្នាក់ធ្វើខុសសីលធម៌ ខ្មែរក្រហមនឹងដកយកទៅស្ទឹងមានជ័យ ដើម្បីជីកប្រឡាយ និងលើកទំនប់។

ចូលដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានយកខ្ញុំទៅកំពង់សោមធ្វើជាកម្មករចិនវាស់ស្ទង់ទឹក រហូតដល់ឆ្នាំ១៩៧៩។ ពេលកងទ័ពវៀតណាមចូលដល់ភ្នំពេញ ខ្ញុំរត់កាត់ព្រៃភ្នំស្ទឹងអារ៉ែង និងជួរភ្នំក្រវាញ រហូតមកដល់សំឡូត។ ខ្ញុំបានរស់នៅអូររថក្រោះ និងបានរត់បន្តទៅរស់នៅប្រទេសថៃរយៈពេលមួយឆ្នាំ។ ខ្ញុំបានចូលធ្វើកងទ័ពខ្មែរក្រហមក្នុងឆ្នាំ១៩៨០ ក្នុងភូមិអូររថក្រោះ ស្រុកសំឡូត។

នៅឆ្នាំ១៩៨២ ខ្ញុំបានជាន់មីនស្ពុរ ហើយក៏ឈប់ធ្វើកងទ័ព។ មីនដែលខ្ញុំជាន់គឺជាមីនរបស់ខ្មែរក្រហមគ្នាឯងដែលដាក់បន្កប់។ រហូតដល់ឆ្នាំ១៩៨៤ ក៏មានការវាយប្រយុទ្ធគ្នាម្តងទៀត ហើយខ្ញុំក៏បានរត់ទៅរស់នៅប្រទេសថៃរយៈពេល៣ឆ្នាំ។ ក្រោយមក ខ្ញុំក៏ត្រឡប់មកនៅសំឡូតវិញ។ នៅឆ្នាំ១៩៩៣ ខ្ញុំបានមករស់នៅស្រុកវាលវែងមកដល់បច្ចុប្បន្ន។

ចុងក្រោយ ខ្ញុំស្នើសុំឲ្យក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ជួយចងក្រងជាសហគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការនៅភូមិស្ទឹងថ្មី។ ខ្ញុំក៏សូមស្នើសុំឲ្យជួយជនពិការអាចប្រកបរបរកសិកម្ម ចិញ្ចឹមសត្វ ដាំបន្លែ និងសិប្បកម្ម ត្បាញកន្ទេល ដែលអាចរកចំណូលបានជួយសម្រួលក្នុងជីវភាពប្រចាំថ្ងៃ។

ចំណែកអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួនទៀត បានស្នើសុំឲ្យជនពិការចងក្រងជាក្រុមក្នុងការប្រកបរបរកសិកម្ម និងចិញ្ចឹមសត្វរួមគ្នា ដើម្បីរកចំណូលបន្ថែម ហើយមួយចំនួនទៀតចង់ឲ្យបង្កើតមូលនិធិសម្រាប់ជនពិការ និងស្នើដល់មណ្ឌលសុខភាពឲ្យមានថ្នាំគ្រប់គ្រាន់សម្រាប់ជនពិការ។

# គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖

## កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

*សាំង ចាន់ធូ*



គរុសិស្សមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ចំនួន៤០នាក់ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលបោះពុម្ពផ្សាយដោយព្រះរាជបណ្ណាល័យ ហ្វូនម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពីក្រុមការងារមជ្ឈ-មណ្ឌលឯកសារ ខេត្តកំពង់ចាម។

នៅក្នុងឱកាសនោះ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបានលើកឡើងអំពីសារសំខាន់នៃសៀវភៅ៖ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រសម្រាប់សិស្សានុសិស្ស

សិក្សាឈ្វេងយល់អំពីព្រះរាជកំណត់ត្រារបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងមកកាន់តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅអំឡុងឆ្នាំ១៩៧៣។ លោក ស៊ាង ចិន្តា ក៏បានលើកទឹកចិត្តដល់សិស្សានុសិស្សដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ព្យាយាមអានឲ្យចប់ដើម្បីបង្កើនចំណេះដឹងប្រវត្តិសាស្ត្រ និងរក្សាទុកជាឯកសារប្រវត្តិសាស្ត្រផ្ទាល់ខ្លួន។

បន្ទាប់ពីទទួលបានសៀវភៅ៖ «សាក្សីប្រវត្តិ-សាស្ត្រ» គរុសិស្សបានបង្ហាញអំពីចំណាប់អារម្មណ៍ និងទស្សនយល់ឃើញដូចខាងក្រោម៖

ខ្ញុំឈ្មោះ សុណា ធារ៉ា អាយុ៣៦ឆ្នាំ គឺជាគរុសិស្សឆ្នាំទី២ ឯកទេស ប្រវត្តិវិទ្យា ជំនាន់ទី៣១ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម។ នាងខ្ញុំមានអារម្មណ៍ត្រេកអរយ៉ាងខ្លាំង បន្ទាប់ពីទទួលបាននូវសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ខ្ញុំយល់ថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់ព្រះហត្ថរបស់សម្តេចម៉ែ គឺពិតជាមានសារសំខាន់ចំពោះកូនខ្មែរគ្រប់រូបសម្រាប់យកមកសិក្សាឈ្វេងយល់បន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរ។ នាងខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីសៀវភៅនេះទៅចែករំលែកជាមួយមិត្តភក្តិផ្សេងៗទៀត និងសិស្សានុសិស្សនៅតាមវិទ្យាល័យដែលខ្ញុំនឹងចេញទៅបង្រៀននាពេលខាងមុខនេះ។ ខ្ញុំមានសំណូមពរទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដូចខាងក្រោម៖

- សូមឲ្យមានការបន្តផ្សព្វផ្សាយអំពីសៀវភៅឯកសារប្រវត្តិសាស្ត្រនេះទៅកាន់សិស្សានុ-សិស្សនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា។
- សូមឲ្យមានការចែកជូនសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» ទៅកាន់លោកគ្រូអ្នកគ្រូ សម្រាប់តម្កល់ទុកជាឯកសារប្រវត្តិសាស្ត្រនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យនានា។

ខ្ញុំឈ្មោះ ធា ថុនា អាយុ២៦ឆ្នាំ គឺជាគរុសិស្សឆ្នាំទី២ ឯកទេស ប្រវត្តិវិទ្យា ជំនាន់ទី៣១ នៅមជ្ឈ-មណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម។ ខ្ញុំពិតជាមានកិត្តិយស និងត្រេកអរយ៉ាងខ្លាំងបន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលនិពន្ធដោយ ហ្លួងម៉ែ។ ខ្ញុំយល់ថា សៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» គឺជាឯកសារប្រវត្តិសាស្ត្រយ៉ាងសំខាន់សម្រាប់សិស្សានុសិស្សពីមួយជំនាន់ទៅមួយជំនាន់សិក្សា និងឈ្វេងយល់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន។ ខ្ញុំនឹងយកព័ត៌មានចេញពីសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» ទៅចែករំលែកដល់សិស្សរបស់ខ្ញុំ និងនិយាយពីរឿងរ៉ាវប្រវត្តិសាស្ត្រដែលខ្ញុំយល់ដឹងកន្លងមកប្រាប់ដល់សិស្ស និងក្មេងៗជំនាន់ក្រោយឲ្យបានដឹងពីប្រវត្តិសាស្ត្រកម្ពុជា។ នាងខ្ញុំសូមស្នើសុំសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួន២០ក្បាល ដើម្បីយកទៅតម្កល់នៅវិទ្យាល័យដែលខ្ញុំនឹងទៅបង្រៀននាពេលឆាប់ៗខាងមុខនេះ។

ខ្ញុំឈ្មោះ ជួន ស្រីវីន អាយុ២៦ឆ្នាំ គឺជាគរុសិស្សឆ្នាំទី២ ឯកទេស រូបវិទ្យា-គីមីវិទ្យា ជំនាន់ទី៣១ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម។ នាងខ្ញុំមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំង បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់ព្រះហត្ថរបស់ហ្លួងម៉ែ។ នាងខ្ញុំនឹងយកចំណេះដឹងប្រវត្តិសាស្ត្រដែលទទួលបានពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ទៅចែករំលែកជាមួយសិស្ស និងបងប្អូនរបស់ខ្ញុំ។ ខ្ញុំស្នើសុំសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួន២០ក្បាល ដើម្បីយកទៅតម្កល់នៅបណ្ណាល័យនៃវិទ្យាល័យដែលខ្ញុំនឹងទៅបង្រៀននាពេលខាងមុខ។

ខ្ញុំឈ្មោះ សាយ សុខហ៊ាង មានអាយុ២១ឆ្នាំ គឺជាគរុសិស្សឆ្នាំទី២ ឯកទេស រូបវិទ្យា-គីមីវិទ្យា ជំនាន់ទី៣១ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម។ នាងខ្ញុំពិតជាមានកិត្តិយសដែលបាន

ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» បោះពុម្ពផ្សាយដោយព្រះរាជបណ្ណាល័យ ហ្វូនម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ នាងខ្ញុំស្នើសុំសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួន២០ក្បាលដើម្បីយកទៅតម្កល់នៅបណ្ណាល័យនៃវិទ្យាល័យដែលនាងខ្ញុំនឹងចេញទៅបង្រៀននាពេលខាងមុខ។

ខ្ញុំឈ្មោះ មៀន ពៅ អាយុ៣០ឆ្នាំ គឺជាគរុសិស្សឆ្នាំទី២ ឯកទេសភាសាអង់គ្លេសជំនាន់ទី៣១ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម។ ក្រោយពីទទួលបានសៀវភៅ៖ «សាក្សីប្រវត្តិសាស្ត្រ» ខ្ញុំមានអារម្មណ៍រំភើបណាស់ ពីព្រោះសៀវភៅនេះគឺជាឯកសារប្រវត្តិសាស្ត្រដ៏សំខាន់សម្រាប់រូបខ្ញុំដែលជាគ្រូបង្រៀននាពេលអនាគត។ សៀវភៅនេះបានរំពុកដល់ស្នាព្រះហស្តរបស់ទ្រង់ទាំងពីរ។ ខ្ញុំនឹងយកព័ត៌មានដែលខ្ញុំដឹងពីសៀវភៅនេះទៅចែករំលែកដល់មិត្តភក្តិនិងសិស្សានុសិស្សនៅវិទ្យាល័យដែលខ្ញុំបង្រៀន និងបងប្អូនអ្នកភូមិ។ ជាចុងក្រោយ ខ្ញុំស្នើសុំសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួន៥០ក្បាល ពីព្រះរាជបណ្ណាល័យ ហ្វូនម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីតម្កល់នៅបណ្ណាល័យនៃវិទ្យាល័យដែលខ្ញុំនឹងត្រូវទៅបង្រៀននៅពេលខាងមុខ។





គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិស្សានុសិស្សនៃអង្គការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន (OBT) ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

សាំង ចាន់ធូ



សិស្សានុសិស្សនៃអង្គការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន (OBT) ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមកាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃអាទិត្យ ទី៦ ខែមិថុនា ឆ្នាំ២០២៣ សិស្សានុសិស្សនៃអង្គការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន(OBT) ចំនួន៥៧ នាក់ ធ្វើដំណើរទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែល ជាសាខារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជំរុញដល់ការយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាផ្តល់ឱកាសដល់សិស្សា-នុសិស្សឲ្យចូលរួមពិភាក្សា និងសិក្សាឈ្វេងយល់អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ សិស្សានុសិស្សអង្គការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន ទទួលបានកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម រួមមាន ៖ ការបង្ហាញអំពីពិព័រណ៍ ការចាក់បញ្ចាំងវីដេអូឯកសារ ការធ្វើទស្សនកិច្ចសិក្សាទៅកាន់ទីតាំងសម្លាប់ប្រជាជនក្នុងរបបខ្មែរក្រហម និងការចែកជូនសៀវភៅប្រវត្តិសាស្ត្រ។ ជាកិច្ចចាប់ផ្តើមលោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារ




សិស្សានុសិស្សនៃអង្គការបណ្ដុះបណ្ដាលថ្នាក់មូលដ្ឋាន (OBT) ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមកាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខេត្តកំពង់ចាម បានដឹកនាំសិស្សានុសិស្សទស្សនាពិព័រណ៍រូបថតចំនួន១០ផ្ទាំងធំៗ ដែលបង្ហាញអំពីប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន ការធ្វើការងារនៅការដ្ឋានទំនប់ និងការវិលត្រឡប់មកស្រុកកំណើតវិញរបស់ប្រជាជនកម្ពុជា បន្ទាប់ពីការដួលរលំរបបខ្មែរក្រហមនៅដើមឆ្នាំ១៩៧៩។

ជាកិច្ចបន្ទាប់លោក សាំង ចាន់ធូ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលបន្ទុកផ្នែកអ្នកស្ម័គ្រចិត្តកម្ពុជា បន្តដឹកនាំសិស្សានុសិស្សចូលទស្សនាបណ្ណាល័យ ដែលមានតម្កល់ទុកឯកសារប្រវត្តិសាស្ត្រខ្មែរក្រហម។ ឆ្លៀតក្នុងឱកាសនោះ លោក សាំង ចាន់ធូ រៀបរាប់អំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ភ្ជាប់ជាមួយទិដ្ឋភាពពីមូលដ្ឋានដែលត្រូវបានស្រាវជ្រាវ និងសរសេរដោយអ្នកស្ម័គ្រចិត្តកម្ពុជានៅខេត្តកំពង់ចាម។ តមក លោក ស៊ាង ចិន្ដា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បាននាំសិស្សានុសិស្សទាំងអស់ចូលមកកាន់សាលពិព័រណ៍រូបថត ដែលមានការដាក់តាំងបង្ហាញអំពីព្រះឆាយាល័ក្ខណ៍ចំនួន១៨ ដែលជាផ្នែកមួយនៃពិព័រណ៍ «សុបិន្តកម្ពុជា»។ បន្ទាប់ពីបានដើរទស្សនាពិព័រណ៍ «សុបិន្តកម្ពុជា» សិស្សានុសិស្សទាំងអស់បានទស្សនាវីដេអូឯកសារ ដែលមានចំណងជើងថា «កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» ដែលរំពុកអំពីតន្ត្រី វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។

កម្មវិធីពេលរសៀលនៃដំណើរទស្សនកិច្ចនេះ គឺការចុះទៅកាន់ទីតាំងអតីតសមរភូមិរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ដែលចាប់ផ្ដើមពីម៉ោង១:៣០នាទី និងបញ្ចប់នៅវេលាម៉ោង៣:៣០នាទីរសៀល។ សិស្សានុសិស្សបានចុះទៅដល់វត្តរកាគយ ដែលជាអតីតបន្ទាយទាហាន លន់ នល់ និងទីតាំងសមរភូមិប្រយុទ្ធរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ លោក ស៊ាង ចិន្ដា រៀបរាប់ទៅកាន់សិស្សានុសិស្សអំពីប្រវត្តិព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងមូលដ្ឋាននេះ។

បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស្ថានភាពនៅក្នុងភូមិសាស្ត្រនេះបានផ្លាស់ប្តូរទាំងស្រុង។ អ្នកភូមិជាច្រើនបានចូលរួមបាតុកម្មដង្ហែទៅកាន់ទីរួមខេត្តកំពង់ចាម និងបន្តទៅទីក្រុងភ្នំពេញ។ នៅចុងឆ្នាំ១៩៧០ កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ និងសុំស្នាក់នៅក្រោមផ្ទះអ្នកភូមិ។ បន្ទាប់មក ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ចាប់ផ្តើមប្រយុទ្ធគ្នា។ ទាហាន លន់ នល់ ត្រូវបានបញ្ជូនមកកាន់បន្ទាយទាហាននៅក្នុងវត្តរការគយ ដើម្បីទប់ទល់ជាមួយកងទ័ពរំដោះខ្មែរក្រហម។ នៅចុងឆ្នាំ១៩៧១ និងដើមឆ្នាំ១៩៧២ បន្ទាយទាហានលន់ នល់ នៅវត្តរការគយ ត្រូវបានវាយបែក និងរំដោះដោយកងទ័ពរំដោះខ្មែរក្រហម។ វត្តរការគយត្រូវបានប្រើប្រាស់ទៅជាកន្លែងព័ស្តុភាររបស់កងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវបានព័ទ្ធជុំវិញដោយកងទ័ពរំដោះខ្មែរក្រហម។ ក្នុងស្ថានភាពបែបនេះ ទាហានលន់ នល់ ប្រើប្រាស់ផ្លូវទឹកដែលជាច្រកចេញចូលសំខាន់ក្នុងការដឹកជញ្ជូនសម្ភារសឹក ស្បៀង និងប្រជាជននៅទីរួមខេត្តកំពង់ចាមចេញទៅកាន់ទីក្រុងភ្នំពេញ តាមរយៈនាវាម៉ារីនទាហាន លន់ នល់ ដែលតែងតែរងការវាយប្រហារពីសំណាក់កងទ័ពរំដោះខ្មែរក្រហម។

ជាកិច្ចបញ្ចប់នៃដំណើរទស្សនកិច្ចសិក្សានេះ លោក លី ដេវីត និងលោក សាំង ចាន់ធូ បានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» សម្រាប់សិស្សយកទៅអានដើម្បីសិក្សាឈ្វេងយល់ និងប្រើប្រាស់ជាឯកសារប្រវត្តិសាស្ត្រ។






សិស្សានុសិស្សនៃអង្គការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន (OBT) ទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមកាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកោះសូទិន ទទួលសៀវភៅ

## «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»

**លី វេជវីត**



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកោះសូទិន ទទួលបានសៀវភៅកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារ មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម កាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពង់ចាមចំនួន៥០នាក់ មកពីឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដែលបោះពុម្ពផ្សាយដោយបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

នៅអំឡុងពេលចែកសៀវភៅ ៖ «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បញ្ជាក់អំពីសារសំខាន់នៃសៀវភៅនេះ ដែលជាឯកសារសម្រាប់ការសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រចេញពីព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងមកកាន់

តំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅអំឡុងឆ្នាំ១៩៧៣។

បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ» អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖



ខ្ញុំឈ្មោះ ម៉ៅ វណ្ណា អាយុ៦៣ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សព្វថ្ងៃរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ បន្ទាប់ពីទទួលបានសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ដែលជាព្រះរាជនិពន្ធផ្ទាល់របស់ ហ្វូងម៉ែ ខ្ញុំពិតជាសប្បាយរីករាយ ខ្លាំងណាស់ ពីព្រោះសៀវភៅនេះគឺជាឯកសារប្រវត្តិសាស្ត្រដែលរូបខ្ញុំផ្ទាល់មិនធ្លាប់បានដឹងអំពីការយាងចូលមកប្រទេសកម្ពុជានៅគ្រាសង្គ្រាមរបស់ទ្រង់ទាំងពីរ។ ខ្ញុំសំណូមពរទៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដល់ប្រជាជនកម្ពុជាឲ្យបានគ្រប់គ្នា។



ខ្ញុំឈ្មោះ ឡឿន គីមសាន គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សព្វថ្ងៃគឺជាមេភូមិ ភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយ ពីព្រោះខ្ញុំបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត» នេះ។ ខ្ញុំនឹងបន្តផ្សព្វផ្សាយអំពីសៀវភៅនេះទៅកាន់គ្រួសារ និងអ្នកភូមិទី៨ផ្សេងទៀត។ ខ្ញុំសំណូមពរទៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តកិច្ចការងារចែកសៀវភៅទៅកាន់អ្នកភូមិទី៨គ្រប់ៗគ្នា។



ខ្ញុំឈ្មោះ ហេង សាន អាយុ៤៨ឆ្នាំ គឺជាគ្រូបង្រៀនរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំសប្បាយរីករាយដែលបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» និងអាចយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ខ្ញុំយល់ថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាឯកសារដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ ដែលកើតមិនទាន់ជំនាន់នោះ អាចអាន និងឈ្វេងយល់បន្ថែម ។ ខ្ញុំនឹងយកព័ត៌មានដែលខ្ញុំដឹងពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ទៅនិយាយប្រាប់សមាជិកគ្រួសារ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ ជាចុងក្រោយ ខ្ញុំសូមសំណូមពរទៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់សៀវភៅប្រវត្តិសាស្ត្រផ្សេងទៀតដល់សិស្សានុសិស្សដើម្បីអាន។





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកោះសូទិន ទទួលបានសៀវភៅកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ពីក្រុមការងារ មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម កាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ពាមជីកង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ»

*សាំង ចាន់ធូ និង លី ដេវីត*



នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ ៖ «សាក្សីប្រវត្តិសាស្ត្រ»៖ កំណត់ហេតុរបស់ សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាល ដល់សិស្សានុសិស្ស ដែលកំពុងសិក្សាថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ក្នុងស្រុកកងមាស ខេត្តកំពង់ចាម។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ៖ សៀវភៅកំណត់ហេតុរបស់ សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាល ដល់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុនសែន ពាមជីកង ក្នុងស្រុកកងមាស ខេត្តកំពង់ចាម។

លោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមលើកឡើងអំពីសារសំខាន់នៃសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាឯកសារប្រវត្តិសាស្ត្រ សម្រាប់សិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយ សិក្សាឈ្វេងយល់ចេញពីព្រះរាជកំណត់ហេតុរបស់ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះរាជដំណើរអមសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងមកទស្សនកិច្ចតំបន់រំដោះនៃរណសិរ្សរួបរួមជាតិកម្ពុជា



នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ ៖ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ សម្តេចព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាល ដល់សិស្សានុសិស្ស ដែលកំពុងសិក្សាថ្នាក់ទី១២នៃ វិទ្យាល័យ ហ៊ុន សែន ពាមជីកង ក្នុងស្រុកកងមាស ខេត្តកំពង់ចាម។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ឆ្នាំ១៩៧៣។ លោក លី ដេវីត លើកទឹកចិត្តសិស្សានុសិស្សដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ព្យាយាមអានឲ្យចប់ដើម្បីបង្កើនចំណេះដឹងប្រវត្តិសាស្ត្រ និងរក្សាទុកជាឯកសារប្រវត្តិសាស្ត្រផ្ទាល់ខ្លួន។

ឆ្លៀតឱកាសនេះ លោក ស៊ាន សុផល នាយកស្តីទីនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង និងគណៈគ្រប់គ្រងវិទ្យាល័យ ថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានផ្តល់សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដែលជាឯកសារប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់ដល់សិស្សានុសិស្ស។ លោកនាយកស្តីទី ស៊ាន សុផល បន្តថា «សាក្សីប្រវត្តិសាស្ត្រ» នឹងតម្កល់ទុកនៅបណ្ណាល័យ ដើម្បីអនុញ្ញាតដល់សិស្សានុសិស្សទាំងអស់ធ្វើការសិក្សាស្រាវជ្រាវ។

បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» សិស្សានុសិស្សបង្ហាញចំណាប់អារម្មណ៍ និងទស្សនយល់ឃើញដូចខាងក្រោម៖

ឡុង ចាន់លីនដា អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រពិត នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង រៀបរាប់ថា ក្រោយពីបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំង។ ខ្ញុំសូមអរព្រះគុណដល់សម្តេចម៉ែ ដែលបានរាជានុញ្ញាតឲ្យ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ព និងចែកសៀវភៅនេះ។ ខ្ញុំនឹងចែករំលែកចំណេះដឹងពីក្នុងសៀវភៅនេះជាមួយអ្នកជិតខាងនិងមិត្តរួមថ្នាក់ៗ ខ្ញុំសំណូមពរ

ទៅកាន់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជួយផ្តល់សៀវភៅផ្សេងៗទៀតសម្រាប់សិស្សវិទ្យាល័យពាមជីកងអាន និងទុកតម្កល់នៅបណ្ណាល័យ។

ស៊ឹម ដូ ឡា អាយុ ១៧ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រពិត នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង ឲ្យដឹងថា ខ្ញុំពិតជាមានមោទនភាពខ្លាំងណាស់ដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់របស់សម្តេចយាយ។ សៀវភៅនេះ ពិតជាមានតម្លៃ និងសំខាន់ខ្លាំងណាស់ សម្រាប់មនុស្សជំនាន់ក្រោយ ជាពិសេស សិស្សនិស្សិត និងអ្នកសិក្សាស្រាវជ្រាវ។

វណ្ណា រិតណាក់ អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រពិត នៅវិទ្យាល័យ ហ៊ុនសែនពាមជីកង និយាយថាបន្ទាប់ពីទទួលបានសៀវភៅ«សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់របស់សម្តេចម៉ែ ខ្ញុំមានអារម្មណ៍រំភើបក្រៃលែង។ សៀវភៅនេះបានរៀបរាប់ពីប្រវត្តិសាស្ត្រសំខាន់ៗ។ ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីការអានសៀវភៅសាក្សីប្រវត្តិសាស្ត្រទៅចែករំលែកជាមួយឪពុកម្តាយ ពូ មីង។ ខ្ញុំសំណូមពរទៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់សៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជាដល់ក្មេងជំនាន់ក្រោយដើម្បីអាន។

ស្រួយ អ៊ាងលី អាយុ ១៨ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រពិត នៅវិទ្យាល័យ ហ៊ុនសែនពាមជីកង បានប្រាប់ថា ខ្ញុំមានអារម្មណ៍រំភើបព្រោះបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» យកមកអាន និងឈ្វេងយល់នូវប្រវត្តិសាស្ត្រដែលខ្ញុំមិនធ្លាប់ឆ្លងកាត់ពីមុនមក។ ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីសៀវភៅសាក្សីប្រវត្តិសាស្ត្រនេះទៅចែករំលែកជាមួយប្អូនៗជំនាន់ក្រោយដែលពុំធ្លាប់បានសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំសំណូមពរទៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាជួយណែនាំ និងពន្យល់សិស្សឲ្យយល់ពីប្រវត្តិសាស្ត្រកម្ពុជាឲ្យបានច្រើន។

ភី ស្រីពេជ្រ អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រពិត នៅវិទ្យាល័យ ហ៊ុន សែនពាមជីកង រៀបរាប់ថា បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់របស់សម្តេចម៉ែ ខ្ញុំមានអារម្មណ៍រំភើប។ ខ្ញុំយល់ថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជនិពន្ធផ្ទាល់របស់សម្តេចម៉ែ គឺជាជំនួយដ៏សំខាន់មួយ សម្រាប់ការសិក្សារបស់ខ្ញុំ។ ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ទៅចែករំលែកជាមួយបងប្អូនមិត្តភ័ក្តិ។ ខ្ញុំសំណូមពរព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជួយផ្តល់សៀវភៅប្រវត្តិសាស្ត្រផ្សេងៗដល់សិស្សានុសិស្សវិទ្យាល័យពាមជីកង។





នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ ៖ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១០០ក្បាលដល់សិស្សានុសិស្ស ដែលកំពុងសិក្សាថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ក្នុងស្រុកកងមាស ខេត្តកំពង់ចាម។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ

## របស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនសិស្សនៅវិទ្យាល័យក្រពើពីរ និងវិទ្យាល័យ ហ៊ុន សែន ភ្នំក្រវាញ

**ឡុង ដានី**



ក្រុមការងាររមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូអ្នកគ្រូសិស្សានុសិស្សនៃវិទ្យាល័យស្រុកវាលវែង និង ស្រុកក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២០៥ ក្បាល ជូនសិស្សានុសិស្សថ្នាក់ទី១០, ១១ និង១២ នៃវិទ្យាល័យក្រពើពីរស្រុកវាលវែង និងវិទ្យាល័យ ហ៊ុន សែន ភ្នំក្រវាញ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

នៅវេលាពេលព្រឹក ថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០២៣ ក្រុមការងាររមជ្ឈមណ្ឌលផ្សះផ្សាវាលវែងធ្វើដំណើរទៅកាន់វិទ្យាល័យក្រពើពីរក្នុងឃុំក្រពើពីរស្រុកវាលវែងខេត្តពោធិ៍សាត់ ដើម្បីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៨៦ក្បាល ជូនសិស្សានុសិស្សចំនួន៨៦នាក់ នៅវិទ្យាល័យក្រពើពីរ។ នៅវេលាម៉ោង២រសៀលថ្ងៃដដែល ក្រុមការងាររមជ្ឈមណ្ឌលផ្សះផ្សាវាលវែង

បានបន្តដំណើរទៅទៅវិទ្យាល័យ ហ៊ុន សែន ភ្នំក្រវាញ ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដោយបានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១១៩ក្បាល ដល់សិស្សានុ-សិស្សថ្នាក់ទី១១ និងទី១២ ចំនួន១១៩នាក់ នៃវិទ្យាល័យ ហ៊ុន សែន ភ្នំក្រវាញ ។

មុនពេលចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម សីហនុដល់សិស្សានុសិស្ស លោកនាយកវិទ្យាល័យក្រពើពីរ ភន ដានិត បានទទួលស្វាគមន៍ និងមានប្រសាសន៍ថា ថ្ងៃនេះវិទ្យាល័យក្រពើពីរមានកិត្តិយសណាស់ដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងនាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» មកចែកជូនសិស្សានុសិស្សក្នុងវិទ្យាល័យក្រពើពីរ។ លោកគ្រូ ភន ដានិត បានផ្ដាំផ្ញើសិស្សានុសិស្សទាំងអស់ឲ្យយកចិត្តទុកដាក់អានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» នេះឲ្យចប់ពីព្រោះសៀវភៅនេះមានសារសំខាន់ និងជាជំនួយបន្ថែមនៅពេលសិស្សសិក្សាមុខវិទ្យាប្រវត្តិសាស្ត្រអំពីប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានណែនាំខ្លួន និងក្រុមការងារដល់លោកគ្រូ និងសិស្សានុសិស្សថា មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានចាប់ផ្ដើមដំណើរការនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣។ ការិយាល័យមជ្ឈមណ្ឌលផ្សះផ្សាវាលវែងស្ថិតនៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ការបង្កើតមជ្ឈមណ្ឌលផ្សះផ្សាវាលវែង គឺមានគោលបំណងដូចខាងក្រោម៖

១) បង្ហាញអំពីប្រវត្តិសាស្ត្រ និងសង្គ្រាមនៅប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៩០។

២) ពង្រឹងការកសាងសន្តិភាព និងទប់ស្កាត់ជម្លោះតាមរយៈកម្មវិធីអប់រំដែលជាឱកាសសម្រាប់យុវជនរស់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្នុងការចូលរួម។









ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូអ្នកគ្រូសិស្សានុសិស្សនៃវិទ្យាល័យស្រុកវាលវែង និង ស្រុកក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យចែករំលែក និងបង្រៀនក្មេងៗនូវបទពិសោធន៍របស់ខ្លួនដែលធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។

៤) ប្រមែរប្រមូលចងក្រងទីតាំងប្រវត្តិសាស្ត្រយោធារឿងរ៉ាវ និងបទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម។

៥) ជួយសម្របសម្រួលលើគម្រោងការលើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៃមជ្ឈ-មណ្ឌលឯកសារកម្ពុជា។

ជាចុងក្រោយ លោក ឡុង ដានី បានបន្ថែមថា សៀវភៅកំណត់ហេតុនេះ គឺជាព្រះរាជសំណេរដើម និងមិនបានកែសម្រួល ដោយឆ្លុះបញ្ចាំងអំពីព្រះរាជគម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព និងសេចក្តីថ្លៃថ្នូរក្នុងអំឡុងពេលដែលព្រះអង្គអមព្រះរាជដំណើរ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋយាងដំណើរតាមយន្តហោះចេញពីទីក្រុងប៉េកាំងទៅកាន់ទីក្រុងហាណូយ និងទីក្រុងដុងហូយ ខេត្តក័ងប៊ិញនៃប្រទេសវៀតណាម និងយាងបន្តតាមរយៈរថយន្តតាមបណ្តោយផ្លូវលំហូជីមិញទៅកាន់ខេត្តសៀមរាបប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៣។ ព្រះរាជដំណើររបស់ព្រះអង្គទាំងពីរត្រូវចំណាយពេលជាងមួយខែ ដោយបង្ហាញយ៉ាងច្រើនពីសេចក្តីថ្លៃថ្នូរ និងភាពទន់ភ្លន់របស់ព្រះមហាក្សត្រី ទោះជាព្រះរាជដំណើររបស់ព្រះអង្គស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដោយសារសង្គ្រាមនៅក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍នាពេលនោះក្តី។ ព្រះមហាក្សត្រី គឺជាសាក្សីផ្ទាល់ចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងរយៈកាលជាង៧ទសវត្សរ៍កន្លងមក ហើយព្រះអង្គគឺជាតស្សរជនប្រវត្តិសាស្ត្រដ៏លេចធ្លោមួយព្រះអង្គក្នុងអំឡុងពេលនោះ។ ព្រះរាជសំណេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ទ្រង់ ផ្តល់នូវព្រះរាជគម្រិះសង្ខេបអំពីជំពូកដ៏សំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។




ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូអ្នកគ្រូសិស្សានុសិស្សនៃវិទ្យាល័យស្រុកវាលវែង និង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ព្រះសង្ឃ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គ្រូបង្រៀន និងសិស្សានុសិស្ស នៅស្រុកស្អាង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

ផេង ពង្សរ៉ាស៊ី



ព្រះសង្ឃ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គ្រូបង្រៀន និងសិស្សានុសិស្ស នៅស្រុកស្អាង ខេត្តកណ្ដាល ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ពីក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរចំនួន៦០ក្បាល ត្រូវបានចែកជូនដល់ព្រះសង្ឃ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គ្រូបង្រៀន និងសិស្សានុសិស្ស នៃស្រុកស្អាង ខេត្តកណ្ដាល ក្នុងកម្មវិធីជួបជុំនារសៀល ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ នៅក្នុងបរិវេណវត្តព្រែករុនក្រោម ឃុំព្រែកគយ។ កម្មវិធីនេះរៀបចំដោយលោក សម វិចិត្រ គឺគ្រូឧទ្ទេសថ្នាក់ជាតិមុខវិជ្ជាប្រវត្តិសាស្ត្រ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាកិច្ចចាប់ផ្ដើមកម្មវិធី មេឃុំព្រែកគយ បាននិយាយពីប្រវត្តិឆ្លងកាត់របបខ្មែរក្រហមទៅកាន់អ្នកចូលរួមក្នុងកម្មវិធី។ បន្ទាប់មកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ត្រូវបានចែកជូនអ្នកចូលរួមទាំងអស់ដើម្បីអាន។ លោក សម វិចិត្រ បានផ្ដល់ពេលវេលាកន្លះម៉ោងដល់អ្នកចូលរួម ដើម្បីអានសៀវភៅនេះ និងបានឲ្យសិស្សានុសិស្សទាំងអស់ កត់ត្រា និងសួរសំណួរ បន្ទាប់ពីអានរួច ទៅកាន់វាគ្មិន។

បន្ទាប់មក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាបានធ្វើបទបង្ហាញ ខ្លីគឺ៖ ១) ព្រឹត្តិការណ៍រដ្ឋប្រហារជាប្រវត្តិសាស្ត្រនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ២) ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជានៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ៣) មូលហេតុនៃការយាងមកកាន់ប្រទេសកម្ពុជានៅខែមីនា ឆ្នាំ១៩៧៣របស់សម្តេចព្រះ នរោត្តម សីហនុ និងសម្តេចម៉ែ ៤) មូលហេតុនៃការរារាំងរបស់ក្រុមខ្មែរក្រហមចំពោះការយាងមករបស់សម្តេចព្រះ នរោត្តម សីហនុ និងសម្តេចម៉ែ ៥) ការយល់ឃើញរបស់សម្តេចព្រះ នរោត្តម សីហនុ ចំពោះការព្យាយាមរារាំងព្រះអង្គមកកាន់ប្រទេសកម្ពុជា និង ៦) ការពន្យល់ពាក្យ «សាក្សីប្រវត្តិសាស្ត្រ» និងសារសំខាន់ក្នុងការកត់ត្រាកំណត់ហេតុផ្ទាល់ខ្លួន។

នៅចុងបញ្ចប់នៃកម្មវិធី ព្រះសង្ឃ តំណាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គ្រូបង្រៀន និងសិស្សានុសិស្ស ចម្រើនពរ និងថ្លែងអំណរព្រះគុណហ្លួងម៉ែ ព្រមទាំងថ្វាយព្រះពរដល់ហ្លួងម៉ែឲ្យមានព្រះជន្មយឺនយូរដើម្បីគង់ជាម្លប់ដល់កូនចៅទាំងអស់គ្នា។










ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាចែក និងប្រគេនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រះសង្ឃ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកស្អាង ខេត្តកណ្តាល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈូក អួន ៖ កម្មាភិបាលខ្មែរក្រហមទាញកាំបិតដេញកាប់សម្លាប់ខ្ញុំព្រោះរឿងបាយក្តាំង

ផន ខន្ធី



ឈូក អួន ឈ្មោះហៅក្រៅយាយ វង្ស
សព្វថ្ងៃរស់នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឈូក អួន ឈ្មោះហៅក្រៅយាយ វង្ស កើតនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៥៩។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិក្រាំងស្បូវ ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត។ សព្វថ្ងៃខ្ញុំរស់នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ ខ្ញុំមានឪពុកឈ្មោះ ឈូក អាន និងម្តាយឈ្មោះ ម៉ុល គង់ និងមានបងប្អូនចំនួន៥នាក់ ក្នុងនោះស្រីចំនួន៣នាក់។ ខ្ញុំចូលរៀននៅឆ្នាំ១៩៦៦ នៅវត្តបន្ទាស្អិតរហូតដល់ថ្នាក់ទី៩ ពីសង្គមក៏ឈប់រៀន។ នៅអំឡុងឆ្នាំ១៩៧០ នៅក្នុងភូមិក្រាំងស្បូវ និងភូមិដូនយ៉យ មានយន្តហោះទម្លាក់គ្រាប់បែក ទម្លាក់ភ្លើង និងបាញ់រះមកលើផ្ទះប្រជាជនដែលរស់នៅក្នុងភូមិ។ ថ្ងៃខ្លះខ្ញុំលាក់ខ្លួននៅក្នុងទ្រុងមាន់ ដើម្បីគេចពីការទម្លាក់គ្រាប់បែក។ នៅឆ្នាំ១៩៧៣ ខ្ញុំឈប់រៀនជួយធ្វើការងារស្រែចម្ការឪពុកម្តាយ និងរែកបន្លែដើរលក់ ដើម្បីយកថវិកាមកផ្គត់ផ្គង់ជីវភាពគ្រួសាររហូតដល់ឆ្នាំ១៩៧៥។

បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវអង្គការចាត់ឲ្យចូលធ្វើការងារជានារីកងចល័ត លើកទំនប់ឃុំ ដែលមានទីតាំងនៅភូមិក្រាំងស្បូវ ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត។ បន្ទាប់ពីលើកទំនប់នៅទីនោះរួច ប្រធានកងចាត់ឲ្យខ្ញុំទៅលើកទំនប់អាង នៅភូមិត្រពាំងបឹង ឃុំឈូក ស្រុកឈូក វិញម្តង។ បន្ទាប់មកទៀត ប្រធានកងចល័ត បញ្ជូនខ្ញុំទៅលើកទំនប់កោះស្លា ប៉ុន្តែស្ថានភាពរស់នៅកោះស្លាជួបការពិបាកជាខ្លាំង ដោយខ្ញុំមានតែសម្លៀកបំពាក់មួយសម្រាប់ និងកន្សែងធ្វើពីក្រណាត់សំពត់មួយ។ ខ្ញុំត្រូវអង្គការចាត់ឲ្យធ្វើការងារចាប់ពីម៉ោង៤ព្រឹករហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបសម្រាកហូបបាយ។ បន្ទាប់ពី សម្រាកហូបបាយរយៈពេលកន្លះម៉ោងមេកងក៏វាយជួងជាសញ្ញាឲ្យចុះធ្វើការងារបន្តរហូតដល់ម៉ោង៦ល្ងាចទើបបានសម្រាក។ ចំពោះរបបអាហារក្នុងមួយថ្ងៃ ខ្ញុំទទួលបានបាយជាមួយសម្លព្រលិត, សម្លផ្ទីបុ សម្លរល្ពៅ ពីរពេល។ ដោយសារតែកង្វះអាហារនិងធ្វើការងារហួសកម្លាំង ខ្ញុំក៏ធ្លាក់ខ្លួនឈឺហើមជើង និងរាងកាយមានសភាព

ស្គម ស្គាំងសល់តែស្បែកដណ្តប់ឆ្អឹងៗ ថ្ងៃខ្លះ ខ្ញុំឃ្លានពេកក៏ហូបត្រួយផ្ទីកជំនួសបាយៗ ក្រោយមក ខ្ញុំក៏ធ្លាក់ខ្លួនឈឺធ្ងន់ ប្រធានកងចល័តនារីរបស់ខ្ញុំឈ្មោះ យាយ យើង និងយាយ កឿន បានបញ្ជូនខ្ញុំមកសម្រាកព្យាបាលនៅមន្ទីរបំប៉ន ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងវ៉ាយៗ

មានថ្ងៃមួយម្តាយរបស់ខ្ញុំឈឺ ខ្ញុំសូមច្បាប់ពីប្រធានកងចល័ត ដើម្បីទៅមើលម្តាយ ឈឺនៅសហករណ៍ភូមិក្រាំងស្បូវៗ មុននឹងប្រធានកងអនុញ្ញាតច្បាប់ឲ្យខ្ញុំ គាត់នៅពិចារណា និងស៊ើបទៅប្រធានភូមិថាម្តាយរបស់ខ្ញុំឈឺពិតប្រាកដមែនទើបយល់ព្រមឲ្យខ្ញុំឈប់បានមួយថ្ងៃទៅមើលម្តាយ ឈឺៗ ពេលខ្ញុំដើរទៅដល់ផ្ទះ ម្តាយរបស់ខ្ញុំក៏ត្រឡប់មកពីពេទ្យវិញៗ ម្តាយរបស់ខ្ញុំបានលួចយកបាយក្តាំងពីរោងបាយសហករណ៍យកមកឲ្យខ្ញុំយកទៅ ហូបនៅកន្លែងធ្វើទំនប់កោះស្វាៗ ពេលខ្ញុំដើរត្រឡប់មកវិញ បានជួបនឹងប្រធានកង ដឹងថាខ្ញុំយកបាយក្តាំងពីរោងបាយសហករណ៍មកតាមខ្លួនៗ ក្រុមគណៈកងទាញកាំបិតហាន់ដើមចេកដេញកាប់ខ្ញុំៗ ខ្ញុំក៏យកបាយក្តាំងទៅ ទុកនៅរោងសហករណ៍វិញៗ គណៈកងគំរាមខ្ញុំថា ប្រសិនខ្ញុំហ៊ានយកបាយក្តាំងនោះទៅ នឹងសម្លាប់ម្តាយខ្ញុំចោលៗ នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមក៏បានវាយលុកចូល ពេលនោះខ្ញុំលួចរត់ចេញពីកងចល័តៗ ខ្ញុំរត់ឡើងទៅលើភ្នំនៅណុប និងភ្នំលះបង់ ក៏បានជួបជាមួយ ទាហានវៀតណាមៗ ទាហានវៀតណាមបានបញ្ជូនខ្ញុំទៅឲ្យប្រធានភូមិឈើទាល ឃុំឈើទាល ស្រុកឈូកៗ បន្ទាប់ពីឆ្នាំ១៩៧៩ ខ្ញុំវិលត្រឡប់មកស្រុកកំណើត និងរស់នៅជួបជុំជាមួយម្តាយវិញៗ ខ្ញុំប្រកបការងារធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃៗ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងប្អូនចំនួន៣នាក់ ដោយស្លាប់ម្នាក់ឈ្មោះ ឈូក សារ៉ែន និងពីរនាក់ទៀតបាត់ដំណឹងរហូតមកដល់បច្ចុប្បន្នមិនដឹងថានៅរស់រានមានជីវិត ឬស្លាប់នោះទេៗ

ឈូក អូន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ផន វន្នី អ្នកស្ម័គ្រចិត្តកម្ពុជានៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពតៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សិស្សានុសិស្សវិទ្យាល័យនេតយ៉ង់ ទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងទីតាំងប្រវត្តិសាស្ត្រ

ស្វួក វិចិត្រ





នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន២៩ នាក់នៃវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង ដឹកនាំដោយអង្គការអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់ (GIZ) ធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងទីតាំងប្រវត្តិសាស្ត្រមួយចំនួនស្ថិតក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន២៩ នាក់នៃវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង ដឹកនាំដោយអង្គការអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់ (GIZ) បានធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងទីតាំងប្រវត្តិសាស្ត្រមួយចំនួនស្ថិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ដំណើរទស្សនកិច្ចសិក្សានេះ ធ្វើឡើងមានគោលបំណងឈ្វេងយល់អំពីរឿងរ៉ាវប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួន នៅស្រុកអន្លង់វែង ដែលធ្លាប់ជាអតីតតំបន់ផ្ទុះនូវភ្លើងសង្រ្គាមរបស់ខ្មែរក្រហមតស៊ូប្រឆាំងជាមួយរាជរដ្ឋាភិបាលកម្ពុជា។

ដំបូងឡើយ ក្រុមសិស្សានុសិស្សបានផ្តោតទៅលើទីតាំងប្រវត្តិសាស្ត្រដំបូងបង្អស់នៅក្នុងដំណើរទស្សនកិច្ចរបស់ខ្លួនគឺនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលជាអតីតផ្ទះប្រជុំរបស់តាម៉ុកនៅលើភ្នំដងរែកៗ បន្ទាប់មក សិស្សានុសិស្សក៏បានធ្វើដំណើរបន្តទៅកាន់ផ្ទះលាក់ខ្លួនរបស់ប៉ុល ពត និងខៀវ សំផន ស្ថិតនៅក្បាលទន្សោង, ទីតាំងបូជាសពប៉ុល ពត នៅ

ក្បែរច្រកជាំ-ស្រង៉ាំ, ទីតាំងបូជាសព សុន សេន និងក្រុមគ្រួសារ នៅជិតវត្តស្រះឈូក និងសារមន្ទីរតាម៉ុក ស្ថិតនៅ ទីរួមស្រុកអន្លង់វែង ព្រមទាំងធ្វើការសិក្សាឈ្វេងយល់បន្ថែមអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងស្រុកអន្លង់វែង។










នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន២៩ នាក់នៃវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបង ដឹកនាំដោយអង្គការអភិវឌ្ឍន៍អន្តរជាតិអាល្លឺម៉ង់ (GIZ) ធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងទីតាំងប្រវត្តិសាស្ត្រមួយចំនួនស្ថិតក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ ចូលរួមទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

មេក វិន





នៅខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីពី «សន្តិភាពនិងសិទ្ធិមនុស្ស» ដល់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ នៃខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីពី «សន្តិភាពនិងសិទ្ធិមនុស្ស» សម្រាប់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ នៃខេត្តឧត្តរមានជ័យ។ ទស្សនកិច្ចសិក្សានេះធ្វើឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងទៅលើផ្នែកប្រវត្តិសាស្ត្រខ្មែរក្រហមដល់យុវជន ការកសាងសន្តិភាព និងការផ្សះផ្សា។

លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើការសម្របសម្រួលក្នុងដំណើរទស្សនកិច្ចសិក្សានេះ និងធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្សដោយផ្តោតសំខាន់ទៅលើកិច្ចការងាររស្នូលរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានអនុវត្តកន្លងមក ជាពិសេសលើកយកនូវបរិបទប្រវត្តិសាស្ត្រជុំវិញការកកើតរបបខ្មែរក្រហម សោកនាដកម្មក្រោមរបបឃោរឃៅ និងការបិទបញ្ចប់នូវទំព័រប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនោះដែរ បណ្ឌិត លី សុខឃាង ចាក់បញ្ចាំងកុនឯកសារមន្ទីរស-២១ ឲ្យគុកទួលស្លែងឲ្យសិស្សានុសិស្សទស្សនា និងឈ្វេងយល់បន្ថែមពីការធ្វើទារុណកម្មអ្នកទោសដែលជាប់ឃុំឃាំងនៅទីនោះ។







*នៅខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីពី «សន្តិភាពនិងសិទ្ធិមនុស្ស» ដល់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ នៃខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

បន្ទាប់ពីទស្សនាកុនឯកសារមន្ទីរស-២១រួចមក សិស្សានុសិស្សសម្តែងនូវអារម្មណ៍រន្ធត់ និងសោកសៅ នៅពេលឃើញទិដ្ឋភាពអ្នកទោសដេកស្លាប់នៅក្នុងបន្ទប់ឃុំឃាំង ដោយជើង និងដៃជាប់ខ្នោះ និងអ្នកទោសខ្លះទៀតត្រូវបានសម្លាប់ វះពោះ និងអារក។បន្តមកទៀតសិស្សានុសិស្សទស្សនាភាពយន្តឯកសារ ដែលរៀបរាប់អំពីរឿងរ៉ាវជីវិតរបស់អតីតអ្នកទោសចំនួនពីរនាក់ និងឆ្នាំសន្តិសុខមន្ទីរស-២១ ព្រមទាំងទស្សនាពិព័រណ៍ស្តីអំពី«សង្គ្រាម និងអំពើប្រល័យពូជសាសន៍» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

កម្មវិធីបន្ទាប់ សិស្សានុសិស្សទៅទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រនៅស្រុកអន្លង់វែងរួមមាន៖ ទីតាំងបូជាសព ប៉ុល ពត, ទីតាំងបូជាសព សុន សេន និងក្រុមគ្រួសារ, ចេតិយ តាម៉ុក និងសារមន្ទីរ តាម៉ុក ដើម្បីឈ្វេងយល់ថា តើនៅពេលចលនាខ្មែរក្រហមបានដុតរលត់ទៅ រឿងរ៉ាវ និងភស្តុតាងសេសសល់នៅសហគមន៍អន្លង់វែងបានបង្រៀន និងផ្តុះបញ្ចាំងដល់សិស្សានុសិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវរួមទាំងយុវជនជំនាន់ក្រោយយ៉ាងដូចម្តេចខ្លះ?

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចសិក្សា សិស្សានុសិស្សបានលើកឡើងនូវមតិ និងចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ថន កញ្ញា ភេទស្រី អាយុ១៦ឆ្នាំ គឺជាសិស្សថ្នាក់ទី១០ វិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ រៀបរាប់ថា «ខ្ញុំពិតជាសប្បាយរីករាយពេលដែលបានរៀនប្រវត្តិសាស្ត្រខ្មែរក្រហមដែលបានបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយបានដឹងពីការកាប់សម្លាប់ ពីការរំដោះប្រទេសជាតិពីរបបខ្មែរក្រហម។ ឪពុករបស់ខ្ញុំតែងតែនិយាយរឿងរ៉ាវប្រវត្តិនៃការតស៊ូរបស់គាត់ឲ្យខ្ញុំស្តាប់។ ឪពុកខ្ញុំបាននិយាយប្រាប់ខ្ញុំថា នៅរបបខ្មែរក្រហមគាត់ត្រូវបានខ្មែរក្រហមកេណ្ឌចូលធ្វើជាកងទ័ពនៅអាយុ១៣ឆ្នាំ។ បន្ទាប់ពីគាត់ចូលបម្រើកងទ័ព ការហូបចុករបស់គាត់ចាប់ផ្តើមខ្វះខាត។ នៅពេលខ្ញុំបានស្តាប់សាច់រឿងរបស់ឪពុកខ្ញុំហើយ ខ្ញុំពិតជាមានការអាណិតយ៉ាងខ្លាំង ព្រោះខ្ញុំដែលជាកូនចៅជំនាន់ក្រោយមិនដែលជួបការលំបាក និងការអត់ឃ្លានដូចគាត់ឡើយ។ ខ្ញុំសោកស្តាយយ៉ាងខ្លាំងចំពោះការធ្វើ

ទារុណកម្ម ការវះពោះ ការដាក់ខ្នោះដៃជើង ដាក់ឃុំឃាំងជនរងគ្រោះនៅក្នុងគុកទួលស្លែង និងការសម្លាប់ប្រជាជនស្លូតត្រង់អស់ជាច្រើននាក់របស់ក្រុមខ្មែរក្រហម។ ខ្ញុំនឹងខិតខំរៀនសូត្រយកចំណេះដឹងដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកលូតលាស់ទៅមុខ ថែរក្សាសន្តិភាព និងប្រវត្តិសាស្ត្រហើយធ្វើយ៉ាងណាកុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត»។

រឿន ស្រីដា គឺជាសិស្សទី១០ លើកឡើងថា «ការរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាល្អខ្លាំងណាស់ ព្រោះយើងជាយុវជនជំនាន់ក្រោយគួរតែដឹងអំពីទុក្ខលំបាករបស់ប្រជាជនខ្មែរដែលឆ្លងកាត់នូវលទ្ធិផ្តាច់ការ អំពើឃោរឃៅ ការបង្អត់អាហារ ការកាប់សម្លាប់ និងការបង្កសង្គ្រាមនៅសម័យនោះ។








នៅខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីពី «សន្តិភាពនិងសិទ្ធិមនុស្ស» ដល់សិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងតាវ នៃខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ស្អាង ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងទំនាក់ទំនងការបរទេសនៅមជ្ឈមណ្ឌលឯកសារកោះថ្ម

សុភ័ក្ត្រ ភាណា





សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុនសែន ស្អាង ចំនួន៤៦នាក់ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងទំនាក់ទំនងការបរទេស នៅមជ្ឈមណ្ឌលឯកសារកោះថ្ម នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣។
( ឈុំ រ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកោះថ្មបានស្វាគមន៍សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុនសែន ស្អាង ចំនួន៤៦នាក់ ដើម្បីជួបជុំពិភាក្សាលើមេរៀនស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងទំនាក់ទំនងការបរទេសនៃរបបនេះ។ វេទិកាថ្នាក់រៀននេះ មានគោលបំណងបំពាក់បំប៉នដល់សិស្សានុសិស្សនូវចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ជាពិសេសប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីលើកកម្ពស់ការត្រិះរិះពិចារណា និងការចង់ចេះចង់ដឹងរបស់សិស្សានុសិស្ស។ វេទិកាថ្នាក់រៀនចាប់ផ្តើមឡើងដោយការធ្វើបទបង្ហាញសង្ខេបដោយលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មអំពីផ្ទាំងពិព័រណ៍រូបភាពប្រវត្តិសាស្ត្រ ដែលតាំងបង្ហាញនៅក្នុងមជ្ឈមណ្ឌលផ្ទាល់។ ពិព័រណ៍រូបថតតាំងបង្ហាញនេះ រួមបញ្ចូលនូវរូបភាពពីមុនរបបខ្មែរក្រហម ក្នុងអំឡុងពេលរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហម។

បន្ទាប់ពីបានស្តាប់ការពន្យល់បកស្រាយអំពីផ្ទាំងពិព័រណ៍ សិស្សានុសិស្សបានទស្សនាភាពយន្តឯកសារក្រោមចំណងជើងថា «ដំណើរឆ្ពោះទៅរកការសង្គ្រោះជាតិ»។ នៅមុនពេលចាប់ផ្តើមថ្នាក់រៀន សិស្សានុសិស្ស ត្រូវបំពេញកម្រងសំណួរស្ទាបស្ទង់មតិមុនថ្នាក់រៀន ដើម្បីវាស់ស្ទង់ចំណេះដឹងរបស់ខ្លួនមុនចូលរៀន។

តមកគ្រូខ ទ្វេស សុភ័ក្រ្ត ភាណា បានប្រើប្រាស់វិធីសាស្ត្របង្រៀនបែបនិទានរឿង ដើម្បីរំលេចអំពីព្រឹត្តិការណ៍ជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយធ្វើការអាននូវសាច់រឿងផ្ទាល់ខ្លួនចំនួនពីររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួនពីររូប។ សិស្សានុសិស្ស បង្ហាញការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះវិធីសាស្ត្រនេះ ព្រមទាំងអាចចងចាំព័ត៌មានច្បាស់ជាងមុន។ បន្ទាប់មកទៀត គ្រូខ ទ្វេសបានធ្វើបទបង្ហាញអំពីតថភាពទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយរំលេចនូវអ្វីដែលបានកើតឡើងនៅក្នុងរបបនោះ។

នៅចុងបញ្ចប់ សិស្សានុសិស្ស បានរៀនសូត្រអំពីទំនាក់ទំនងការបរទេសរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសដទៃ។ ដើម្បីវាស់ស្ទង់ចំណេះដឹងដែលសិស្សានុសិស្សទទួលបានបន្ទាប់ពីចូលរួមនៅក្នុងថ្នាក់រៀននេះ សិស្សានុសិស្ស ត្រូវបានស្នើឲ្យបំពេញកម្រងសំណួរស្ទាបស្ទង់ក្រោយថ្នាក់រៀន។ សិស្សានុសិស្ស ក៏ទទួលបានឱកាសទៅទស្សនាទីតាំងប្រវត្តិសាស្ត្រកោះថ្មX16 និងទទួលបានសៀវភៅបោះពុម្ពថ្មីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា «សាក្សីប្រវត្តិសាស្ត្រ» ដែរ។



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ស្គូល ចំនួន ៤៦នាក់ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងទំនាក់ទំនងការបរទេស នៅមជ្ឈមណ្ឌលឯកសារកោះថ្ម នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» នៅស្រុកអន្លង់វែង

*សួត វិចិត្រ*





នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន៤១នាក់នៃវិទ្យាល័យ ស្រែណូយ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សចំនួន៤១នាក់ នៃវិទ្យាល័យ ស្រែណូយ បានចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាព អន្លង់វែង នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។ វេទិកាថ្នាក់រៀននេះ មានគោលបំណងលើកកម្ពស់ ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់យុវជននិងទប់ស្កាត់អំពើ ប្រល័យពូជសាសន៍នាពេលអនាគត។ លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន ការបង្កើតសហករណ៍, ការរៀបការដោយបង្ខំ, ការ រំលោភសិទ្ធិមនុស្ស និងពលកម្មរបស់កុមារ, ការ ធ្វើបន្សុទ្ធកម្ម និង ការសម្លាប់រង្គាល ដែលបង្កើតបាន ជាការពិភាក្សា និងការសួរសំណួរពីសិស្សានុសិស្ស ដូចតទៅ៖ តើមេដឹកនាំខ្មែរក្រហមមានចរិតផ្តាច់ការ ទាំងអស់ដែរឬទេ? ហេតុអ្វីបានជារបបខ្មែរ ក្រហមលុបបំបាត់អ្នកចេះដឹង? ហេតុអ្វីបានជាមេដឹក នាំខ្មែរក្រហមប្រកាន់យកលទ្ធិកុម្មុយនីស្ត? ហេតុអ្វី បានជាខ្មែរក្រហមមិនឲ្យប្រជាជនហូបចុកគ្រប់គ្រាន់? តើរបបខ្មែរក្រហមមានចំណុចវិជ្ជមានយ៉ាងដូចម្តេច

ខ្លះ? តើខ្មែរក្រហមជានរណា និងឡើងកាន់អំណាចដោយរបៀបណា? ហេតុអ្វីបានជាត្រូវយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោស?

បន្ទាប់មកទៀត បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងធ្វើបទបង្ហាញរយៈពេលជាង១ម៉ោង ដោយផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម។ នៅក្នុងរបបខ្មែរក្រហមប្រជាជនប្រមាណជិត២លាននាក់បានស្លាប់បាត់បង់ជីវិតតាមរយៈការធ្វើការងារដោយបង្ខំក្នុងសហករណ៍ ការធ្វើទារុណកម្ម និងការសម្លាប់រង្គាល ហើយចំនួន៥លាននាក់គឺជាអ្នករស់រានមានជីវិត ដែលជាសាច់ញាតិ និងក្រុមគ្រួសារអ្នកដែលស្លាប់បាត់បង់ជីវិត។ នៅក្នុងវេទិកាថ្នាក់រៀននេះ សិស្សបានសួរសំណួរដូចតទៅ «តើអ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមត្រូវបន្តរស់នៅយ៉ាងដូចម្តេច? តើយើងទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញដោយរបៀបណា? ឆ្លើយតបទៅនឹងសំណួររបស់សិស្សម្នាក់ក្នុងចំណោម៤១នាក់ ដែលលើកឡើងថា«ហេតុអ្វីបានយើងត្រូវដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម?» បណ្ឌិត លី សុខឃាង បានលើកឡើងថា ការអប់រំអំពីប្រវត្តិសាស្ត្រ គឺមានបំណងឲ្យយុវជនចេះគិតពិចារណា និងទទួលបានចំណេះដឹងជាមូលដ្ឋានអំពីមូលហេតុ ដើមចមអំពើឃោរឃៅ និងអំពើប្រល័យពូជសាសន៍ដែលប្រៀបបានទៅនឹងការទប់ស្កាត់នៃអំពើនោះដែរ។

នៅចុងបញ្ចប់វេទិកាថ្នាក់រៀន សិស្សានុសិស្សបានបង្ហាញអំពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

រីម រស្មី ភេទស្រី អាយុ១៨ឆ្នាំ មកពីស្រែណូយ លើកឡើងថា «ការចូលរួមក្នុងវេទិកាថ្នាក់រៀននេះ គឺចង់ឲ្យសិស្សានុសិស្សឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជននាជំនាន់នោះ ថាតើទទួលរងការលំបាកដូចម្តេចខ្លះ? ម្យ៉ាងទៀត កេរដំណែលប្រវត្តិសាស្ត្រនៅអន្លង់វែង គឺពិតជាជួយដល់ការចងចាំ និងការអប់រំដល់យុវជន»។

វីន ផៃ ភេទស្រី អាយុ១៩ឆ្នាំ មកពីស្រែណូយ រៀបរាប់ថា «វេទិកាថ្នាក់រៀននេះពិតជាល្អ ព្រោះខ្ញុំអាចរៀនពីប្រវត្តិសាស្ត្ររបស់សង្គមខ្មែរដែលរងការឈឺចាប់ ការធ្វើបាប និងការជិះជាន់នាពេលកន្លងមក។ ជាងនេះទៅទៀត ខ្ញុំបានឃើញទីតាំងប្រវត្តិសាស្ត្រផ្ទាល់ គឺសារមន្ទីរអតីតផ្ទះតាម៉ុកនៅក្នុងស្រុកអន្លង់វែង ដែលបន្សល់ទុកសម្រាប់មនុស្សជំនាន់ក្រោយបានឈ្វេងយល់។ ខ្ញុំសូមផ្តាំទៅកាន់មិត្តភក្តិផ្សេងទៀតដែលមិនទាន់បានចូលរួមក្នុងវេទិកានេះ ត្រូវមកចូលរួម ព្រោះធ្វើឲ្យយើងដឹងរឿងរ៉ាវដែលសង្គមយើងបានជួបប្រទះ»។



នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ សិស្សានុសិស្សចំនួន ៤១នាក់នៃវិទ្យាល័យស្រែណូយ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិស្ទឹងថ្មី

គីម សុវណ្ណដានី





ក្រុមការងារ «គម្រោងការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងវិញនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែងខេត្តពោធិ៍សាត់។ (ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនរស់នៅភូមិស្ទឹងថ្មីស្ទើរតែទាំងអស់ប្រកបរបរកសិកម្ម ហើយភាគច្រើនដាំពោត និងដំឡូង ដោយសារតែសណ្ឋានដីនៅក្នុងភូមិគឺជាប្រភេទដីទួល ដីភ្នំ និងដីក្រហមៗ នៅក្នុងឆ្នាំ២០២៣នេះ ប្រជាកសិករបានចំណាយប្រាក់ច្រើនក្នុងការធ្វើចម្ការ ដោយសារតែការប្រែប្រួលអាកាសធាតុ ព្រោះដំណាំពោត និងដំឡូង អាចលូតលាស់បានល្អលុះត្រាតែមានទឹកស្រោចស្រពគ្រប់គ្រាន់ៗ នៅពេលប្រជាកសិករចាប់ផ្ដើមដាំដំណាំទាំងនេះនៅដើមរដូវ អាកាសធាតុបានប្រែទៅជារាំងស្ងួត បណ្ដាលឲ្យងាប់កូនដំណាំៗ ដោយឡែកនៅពេលដែលដំណាំចាប់ផ្ដើមចុះមើម និងចេញក្ដិប ភ្លៀងចាប់ផ្ដើមធ្លាក់ជោគជាំរហូតធ្វើឲ្យរលួយមើម និងរលួយក្ដិបៗ តាមសម្ដីរបស់មេភូមិស្ទឹងថ្មី ប៊ុន ស្រីពៅ បានឲ្យដឹងថា ប្រជាជនមានការលំបាកខ្លាំងក្នុងការធ្វើចម្ការ ដោយសារតំបន់ខ្លះមិនទាន់មានផ្លូវធ្វើដំណើរស្រួលបួលនៅឡើយ ដែលជាផលរំខានដល់ប្រជាកសិករនៅរដូវប្រមូលផលដំណាំ ព្រោះត្រូវចំណាយប្រាក់លើការដឹកជញ្ជូនថ្លៃដែលធ្វើឲ្យកសិករមិនបានទទួលផលចំណេញៗ កសិករភាគច្រើនខ្ចីលុយពីធនាគារដើម្បីធ្វើស្រែចម្ការ ប៉ុន្តែនៅពេលដែលផលដំណាំខូចខាត គឺកសិករត្រូវប្រឈមនឹងការសងប្រាក់ធនាគារផង និងផ្គត់ផ្គង់



ក្រុមការងារ «គម្រោងការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងវិញនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែងខេត្តពោធិ៍សាត់។
(ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជីវភាពគ្រួសារផង ដូច្នេះមានពេលខ្លះមេភូមិបានស្វែងរកសុំជំនួយពីមូលនិធិឃុំជួយដល់កសិករដែលខ្វះខាតខ្លាំង។

កន្លងមកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង មានទីតាំងស្ថិតនៅភូមិប្រមោយ ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ បានជ្រើសរើសយកភូមិស្ទឹងថ្មី ដែលស្ថិតនៅឃុំប្រម៉ោយជាមួយគ្នាជាភូមិគោលដៅ សម្រាប់ឲ្យអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៦ ចុះធ្វើការសម្ភាសន៍ប្រជាជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម រួមមាន ស្ត្រីមេម៉ាយ ជនពិការ និងជាជនជាតិភាគតិចព័រ។ បើតាមការឲ្យដឹងពីលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ភូមិស្ទឹងថ្មីគឺជាភូមិដាច់ស្រយាលមួយនៃឃុំប្រម៉ោយ។ កន្លងមកអ្នកស្ម័គ្រចិត្តកម្ពុជាពីរនាក់រស់នៅស្រុកវាលវែង ឈ្មោះ ធី គីមហុង និង ចាន់ណារិទ្ធ បានចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានចំនួន ៧២នាក់ ទាក់ទងនឹងបញ្ហាប្រឈមផ្នែកសុខភាព និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម ក្នុងរយៈពេល៣ខែ។ ដូច្នេះហើយ ទើបក្រុមការងារ គម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» បានរៀបចំវេទិកាចុះពិនិត្យសុខភាពបឋម និងចែកសៀវភៅ «ព័ត៌មានពីការថែទាំសុខភាព» ដល់អ្នកដែលបានផ្តល់បទសម្ភាសន៍ទាំង៧២នាក់ ដែលអ្នកធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

វេជ្ជបណ្ឌិត ឡុង ដារ៉ា ឯកទេសជំងឺទូទៅ និងលោកស្រីគិលានុបដ្ឋាកយិការ អ៊ូ បញ្ញា បានពិនិត្យសុខភាពបឋមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិស្ទឹងថ្មីចំនួន៣៦នាក់ ក្នុងមួយថ្ងៃ ដែលការពិនិត្យសុខភាពបឋមនេះធ្វើឡើងរយៈពេលពីរថ្ងៃជាប់គ្នា គឺថ្ងៃទី១០ និងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣។ ដោយឡែកនៅថ្ងៃដំបូង គឺថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួមទាំងក្រុមគ្រូពេទ្យបានចុះទៅពិនិត្យសញ្ញាណជីវិត និងចង្វាក់បេះដូង ដោយម៉ាស៊ីនពិនិត្យស៊ុយប្រវត្តិ (ECG) ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ទាំង៧២នាក់ ដោយបែងចែកជាពីរក្រុម ក្រុមព្រឹក និងក្រុមរសៀល។

ក្រោយពីការពិនិត្យចប់រួចរាល់ វេជ្ជបណ្ឌិត ឡុង ដារ៉ា បានរកឃើញអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ស្ទើរតែ៩០ភាគរយមានជំងឺលើសឈាម និងជំងឺទឹកនោមផ្អែម។ វេជ្ជបណ្ឌិត ឡុង ដារ៉ា លើកឡើងថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំង៧២នាក់ គួរតែទទួលបានការអប់រំអំពីការថែទាំសុខភាពជាពិសេសតាមរយៈចំណីអាហារ និងការផ្លាស់ប្ដូររបៀបរស់នៅប្រចាំថ្ងៃ។

គុជ ស៊ីថុល ភេទស្រី អាយុ៧២ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី ដែលបានមកពិនិត្យសុខភាពជាមួយក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានមានប្រសាសន៍ថា កម្មវិធីថ្ងៃនេះល្អណាស់ ជាពិសេសបានជួយដល់អ្នកជំងឺដែលមានជីវភាពក្រខ្សត់ ព្រោះអ្នកជំងឺមិនដែលបានទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យឯកជនទេដោយសារខ្វះខាតថវិកា គួបផ្សំនឹងថ្លៃធ្វើដំណើរ។ កម្មវិធីពិនិត្យសុខភាពនេះបានជួយស្រោចស្រង់ជីវិតខ្ញុំ ព្រោះបើខ្ញុំមិនបានពិនិត្យសុខភាព ហើយចេះតែទិញថ្នាំលេបផ្ដេសផ្ដាស់ ធ្វើឲ្យខ្ញុំអស់ថវិកា ហើយជីវិតខ្ញុំក៏ស្លាប់ទៀត។ នៅពេលដែលវេជ្ជបណ្ឌិតមកពិនិត្យសុខភាពឲ្យខ្ញុំផ្ទាល់បែបនេះ ហើយរកឃើញប្រភេទជំងឺ ដូចជា លើសសម្ពាធឈាម លើសសារ-ជាតិស្ករក្នុងឈាម ព្រមទាំងមានការណែនាំ និងចេញវេជ្ជបញ្ជាឲ្យទិញថ្នាំលេបព្យាបាលត្រឹមត្រូវ ព្រមទាំងហូបអាហារល្អនឹងធ្វើឲ្យសុខភាពរបស់ខ្ញុំល្អប្រសើរឡើងវិញ។ ការពិនិត្យសុខភាពនេះ មានប្រយោជន៍ណាស់សម្រាប់ខ្ញុំ ព្រោះធ្វើឲ្យខ្ញុំដឹងថាជំងឺដែលខ្ញុំធ្លាប់មានកន្លងមកបានធូរស្បើយ ឬមានការវិវឌ្ឍន៍ទៅជាធ្ងន់ធ្ងរជាងមុនយ៉ាងណានោះ។ ខ្ញុំមិនដែលបានពិនិត្យសុខភាពដោយឥតគិតថ្លៃបែបនេះទេ។

ចិន បឿន ភេទប្រុស អាយុ៦៨ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី ដែលបានមកពិនិត្យសុខភាពជាមួយក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបរាប់ថា ខ្ញុំមានការពេញចិត្តជាខ្លាំងដែលបានចូលរួមពិនិត្យសុខភាពនៅថ្ងៃនេះ ព្រោះកន្លងមកមិនដែលមានវេទិកា និងមានពេទ្យមកពិនិត្យសុខភាពដល់ប្រជាជនក្នុងភូមិទេ។ ក្រុមគ្រូពេទ្យបានធ្វើរោគវិនិច្ឆ័យ និងចេញវេជ្ជបញ្ជាឲ្យអ្នកភូមិដែលមានជំងឺទៅទិញថ្នាំលេបព្យាបាលឲ្យបានត្រឹមត្រូវថែមទៀត។ កន្លងមកខ្ញុំធ្លាប់ទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាពដោយត្រូវចំណាយថវិកាផ្ទាល់ខ្លួន ប៉ុន្តែនៅថ្ងៃនេះ ខ្ញុំបានពិនិត្យសុខភាពដោយឥតគិតថ្លៃ ថែមទាំងទទួលបានមធ្យោបាយធ្វើដំណើរពីក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថែមទៀតផង។

អ៊ុន ហន ភេទប្រុស អាយុ៦៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី ដែលបានមកពិនិត្យសុខភាពជាមួយក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានឲ្យដឹងថា ខ្ញុំសប្បាយរីករាយដែលបានចូលរួមពិនិត្យសុខភាពថ្ងៃនេះ ជាពិសេសគ្រូពេទ្យពិនិត្យសុខភាពខ្ញុំច្បាស់លាស់ និងប្រាប់ពីប្រភេទជំងឺរបស់ខ្ញុំ ថែមទាំងចេញវេជ្ជបញ្ជាឲ្យខ្ញុំទៅទិញថ្នាំលេបព្យាបាលឲ្យត្រឹមត្រូវ និងចំគោលដៅ។

ជា សារ៉ន ភេទប្រុស អាយុ៦១ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី មានប្រសាសន៍ថា កម្មវិធីនេះល្អណាស់សម្រាប់ជួយដល់មនុស្សចាស់ និងជនពិការ តាមរយៈក្រុមគ្រូពេទ្យចុះមកពិនិត្យស្វែងរកជំងឺរបស់អ្នកភូមិច្បាស់លាស់ និងប្រាប់ពីវិធីថែទាំសុខភាពឲ្យបានប្រសើរជាងមុន។

ជាង ទឹម ភេទប្រុស អាយុ៦៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី លើកឡើងថា សូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានចុះមកជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុច្រើននិងផ្ដល់ជាមធ្យោបាយធ្វើដំណើរមកពិនិត្យសុខភាពនៅថ្ងៃនេះ។ ជាទូទៅទាល់តែខ្ញុំឈឺទើបខ្ញុំទៅពេទ្យ។ នៅពេលក្រុមគ្រូពេទ្យមកពិនិត្យសុខភាពខ្ញុំបែបនេះ អាចឲ្យខ្ញុំដឹង

ពីជំងឺផ្សេងៗជាមុនដើម្បីព្យាបាលទាន់ពេល និងទប់ស្កាត់កុំឲ្យឈានដល់ដំណាក់កាលធ្ងន់ធ្ងរ។

ជា ភាន ភេទប្រុស អាយុ៦៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី ដែលបានមកពិនិត្យសុខភាពជាមួយក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានឲ្យដឹងថា កម្មវិធីនេះគឺល្អណាស់សម្រាប់ខ្ញុំ ព្រោះមានទាំងការពិនិត្យសុខភាព និងមានទាំងការជួយឧបត្ថម្ភមធ្យោបាយធ្វើដំណើរ។ កន្លងមក ខ្ញុំមិនដែលឃើញមានអ្នកចុះមកធ្វើកិច្ចការបែបនេះទេ។ ក្នុងនោះដែរ ខ្ញុំបានយល់ដឹងពីសុខភាពរបស់ខ្ញុំ ជាពិសេសពេលអានសៀវភៅ «ព័ត៌មានពីការថែទាំសុខភាព» ដែលមានរោគសញ្ញាដែលពាក់ព័ន្ធជាមួយខ្ញុំ។ កន្លងមកពេលដែលខ្ញុំទៅមន្ទីរពេទ្យ ខ្ញុំពុំដែលទទួលបានការណែនាំបែបនេះទេ ដូចជាការតមអាហារណាដែលប៉ះពាល់ដល់សុខភាពខ្ញុំផ្ទាល់ ជាក់ស្តែង ដូចជា បារី ស្រា ជាដើម។

យាន ឡឿន ភេទប្រុស អាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី រៀបរាប់ថា កម្មវិធីនេះបានជួយខ្ញុំ ក៏ដូចជាអ្នកភូមិខ្ញុំដែលរស់នៅក្នុងតំបន់ព្រៃភ្នំឲ្យបានយល់ដឹងអំពីការថែទាំសុខភាព និងបញ្ចៀសកុំឲ្យកើតមានជំងឺផ្សេងៗ។ ថ្ងៃនេះគ្រូពេទ្យបានចុះមកពិនិត្យសុខភាពដល់ខ្ញុំ និងចាស់ទុំដែលរស់នៅតំបន់ព្រៃឲ្យបានដឹងពីជំងឺខ្លួន ដើម្បីព្យាបាលឲ្យបានត្រឹមត្រូវដើម្បីបន្តជីវិតទៅថ្ងៃមុខទៀត។

វ៉ន រ៉ម ភេទស្រី អាយុ៦០ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិស៊ឹងថ្មី មានប្រសាសន៍ថា ខ្ញុំមានការត្រេកអរណាស់ដែលក្រុមគ្រូពេទ្យចុះមកជួយពិនិត្យសុខភាព និងពិគ្រោះជំងឺឲ្យខ្ញុំ ព្រោះពេលនេះសុខភាពរបស់ខ្ញុំទ្រុឌទ្រោម ដោយសារកន្លងមកខ្ញុំមិនដែលបានពិនិត្យសុខភាពទេ។ ក្រោយពីការពិនិត្យសុខភាពរួច គ្រូពេទ្យរកឃើញថា ខ្ញុំឡើងឈាម ដែលតម្រូវឲ្យខ្ញុំដំឡើងកម្រិតថ្នាំ និងត្រូវតមអាហារប្រៃ។

ក្រុមការងារ «គម្រោងការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងវិញនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិស៊ឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(ទាវ សម្ផស្ស/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# ការិយាល័យព័ត៌មានសាធារណៈ







«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយ ដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។







មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។







តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។




ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរស័ព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org







សូមអរគុណ!

# អៀង សង ៖ ខ្ញុំបាត់បង់បងស្រីពីរនាក់បន្ទាប់ពីរបបខ្មែរក្រហម

**ផន វណ្ណី**

ខ្ញុំឈ្មោះ អៀង សង ភេទប្រុស អាយុ៦៦ឆ្នាំ កើតនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៥៧។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិដានគោម ឃុំដានគោម ស្រុកអង្គរជ័យ ខេត្តកំពត។ ឪពុករបស់ខ្ញុំឈ្មោះ អៀង ជន និងម្តាយ ឈ្មោះ ចង់ មុត។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៨នាក់ ក្នុងចំណោមនោះស្រីចំនួន ៥នាក់។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។ នៅក្នុងឆ្នាំ១៩៦៣ ខ្ញុំចូលរៀននៅសាលាវត្តអង្គស្តុក។ ខ្ញុំរៀនដល់ថ្នាក់ទី១១ ពីសង្គមចាស់ក៏ឈប់រៀនដើម្បីជួយធ្វើការងារស្រែចម្ការឪពុកម្តាយដែលកំពុងខ្វះខាតខ្លាំង។ នៅចុងទសវត្សរ៍ទី៦០ និងដើមឆ្នាំ១៩៧០ អំឡុងពេលធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីព្រះប្រមុខរដ្ឋ ស្ថានភាពនៅក្នុងភូមិរបស់ខ្ញុំមិនទាន់មានសង្គ្រាម បាញ់ផ្លោង និងការទម្លាក់គ្រាប់បែកនោះទេ។ ក្រោយមក ក្រុមខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិរបស់ខ្ញុំនៅឆ្នាំ១៩៧១។ នៅចន្លោះពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៥ ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យធ្វើការងារស្រែចម្ការ ជីកប្រឡាយ លើកទំនប់ នៅតាមកងចល័ត។ ក្នុងមួយកងចល័តខ្មែរក្រហមបែងចែកចំនួនមនុស្សចាប់ពី៥០នាក់ទៅ១០០នាក់។

នៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៨ឆ្នាំ។ ដោយសារ ខ្ញុំគឺជាប្រជាជនមូលដ្ឋាន ខ្មែរក្រហមចាត់ខ្ញុំឲ្យធ្វើការងារនៅតាមកងចល័តដដែល រហូតដល់ឆ្នាំ១៩៧៧ ទើបខ្មែរក្រហមបញ្ជូនខ្ញុំឲ្យចូលធ្វើកងទ័ព និងបញ្ជូនខ្ញុំទៅឈរជើងការពារនៅតាមព្រំដែនវៀតណាម។ ចំពោះរបបអាហារហូបចុក ខ្ញុំទទួលបានអង្ករបីកំប៉ុង សម្រាប់បបរចែកសមាជិក១០នាក់។ ដោយសារតែភាព




អៀង សង អាយុ៦៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។ (ផន វន្នី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អត់ឃ្លានខ្ញុំក៏ធ្លាក់ខ្លួនឈឺ។ នៅសមរភូមិតាមព្រំដែន កម្ពុជា-វៀតណាម ខ្ញុំរងរបួសដោយសារគ្រាប់កាំភ្លើង និងគ្រាប់ផ្លោងចំដៃស្តាំ និងជើង។ បន្ទាប់ពីនោះ ខ្មែរក្រហមក៏បញ្ជូនខ្ញុំឲ្យមកសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យស្រុកគិរីវង្ស ខេត្តតាកែវ។ ក្រោយមក នៅឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយចូលមក ហើយផ្ទុះសង្គ្រាមជាមួយកងទ័ពខ្មែរក្រហមយ៉ាងខ្លាំង។ ខ្ញុំបានរត់គេចមកដល់ម្តុំអូរចំបក់ រួចក៏ចូលសម្រាកនៅទីនោះប្រហែល៣ទៅ៤យប់ ទាំងរបួសពេញខ្លួន។ បន្ទាប់ពីចេញពីទីនោះ ខ្ញុំក៏ត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមចងមនុស្សផ្អោបគ្នានឹងខ្សែកៅស៊ូ ដោយផ្ទាល់ភ្នែក រួចបញ្ជូនទៅសម្លាប់នៅមន្ទីរតាម៉ន និងភ្នំស្រមោចជាច្រើននាក់។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ខ្ញុំបានរៀបការប្រពន្ធនៅភូមិអង្គខ្លាយ ឃុំដានគោម ស្រុកអង្គរជ័យ ខេត្តកំពត។ ក្រោយពេលរៀបការ ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ និង មានតួនាទីជាសេនាជនភូមិ ដើម្បីការពារភូមិឃុំរបស់ខ្ញុំ។ ក្រោយមកទៀត យោធាខ្មែរក្រហមលួចចូលដើម្បីចាប់មេភូមិ មេឃុំ គ្រូបង្រៀន យកទៅរៀនសូត្រ ប៉ុន្តែពេលចូលមកដល់ក្នុងភូមិមានការផ្ទុះអាវុធជាមួយក្រុមសេនាជនភូមិ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងស្រីអស់ចំនួន ៣នាក់ នៅអំឡុងឆ្នាំ១៩៧៩ ប៉ុន្តែខ្ញុំមិនបានដឹងថាគាត់ស្លាប់ឬរស់ឡើយ ដោយបាត់ដំណឹងមិនឃើញគាត់វិលត្រឡប់មកស្រុកកំណើតវិញរហូតមកដល់សព្វថ្ងៃ។ អារម្មណ៍របស់ខ្ញុំនៅមិនអាចបំភ្លេចរឿងរ៉ាវពីរបបខ្មែរក្រហមបានឡើយ ពេលដែលខ្ញុំនឹកឃើញនូវប្រវត្តិដែលខ្ញុំធ្លាប់ឆ្លងកាត់ម្តងៗ វាហាក់ដូចជារឿងរ៉ាវទាំងនោះទើបនឹងកើតឡើងថ្មីៗ នេះអញ្ចឹង។



អៀង សង អាយុ៦៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ (ផនវន្នី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ទួលពិឃាដ» (ត)

# ១៤. វិញ្ញាណសុបិន

## បែកឆ្ងាយដំណឹងពីរបៀបសម្លាប់ឪពុកម្ដាយ និង ប្អូនភ្លោះខ្ញុំ ព្រោយបិសាចខ្មៅ ស្រែកឈាមជាតិឯង

ក្រោយពីមេឃបាត់ដួងចន្ទ្រ និងសល់តែបាតដៃទទេជីវិតរស់នៅជាក្មេងកំព្រាបីនាក់បងប្អូន ខំប្រឹងតស៊ូយ៉ាងត្រដាបត្រដួសអត់ឃ្លានបានព្រឹកខ្វះល្ងាចទម្រាំស្រូវឲ្យផល។ តែទោះជាយ៉ាងណា យើងមានសំណាងដែលនៅមានជីវិតរស់រានក្រោមការលាក់បំពួនឪពុកម្ដាយ និងតាមថែរក្សាពីព្រលឹងរបស់គាត់ហើយ ខំហាត់ពត់លត់ដំខ្លួនឲ្យក្លាយទៅជាគ្រួសារដ៏ល្អនៅក្រោមដំបូលព្រលឹងមេបាពុកម៉ែ។

រយៈពេលប្រហែលមួយឆ្នាំនៃការរស់នៅក្រោមមេឃដែលគ្មានដួងចន្ទ្រ។ រាត្រីមួយ ខ្ញុំបានសុបិនឃើញឪពុកម្ដាយ។ ពួកគាត់រស់នៅតែពីរនាក់ក្នុងផ្ទះតៀមធ្វើពីដើមឫស្សីផ្ទាល់ដីប្រក់ស្លឹកត្នោត និងគ្រែរនាប ស្ថិតនៅក្បែរផ្លូវខាងលិចទួលស្វាំង មើលទៅផ្ទះនោះដូចជាទើបនឹងធ្វើថ្មីៗ។ ឃើញចង្ក្រានផ្ទោះ ចានឆ្នាំង និងមានត្រីងៀតព្យួរនៅនឹងជញ្ជាំងស្លឹកត្នោត។

ឪពុកស្លៀកខោជ្រួរប្រាំ ពាក់អាវហោប៉ៅបីបង់កក្រមា ម្ដាយស្លៀកសំពត់ ពាក់អាវដៃវែង មានក្រមាដាក់លើស្មា សម្លៀកបំពាក់សុទ្ធតែខ្មៅទាំងអស់។ សភាពគាត់មិនខុសកាលគាត់នៅរស់ទេ គ្រាន់តែពេលនេះមើលទៅដូចជាថ្មីជាង។

ឪពុកអង្គុយលើគ្រែសំយុងជើងទៅក្រោម ឯម្ដាយអង្គុយលើអង្រឹងកំប្លោក ដូចជាកំពុងជជែកគ្នាលេងធម្មតា។ ចំណែកម្ដាយមានសក់កន្ទ្រីងកន្ទ្រើង ប្រឡាក់ដោយកំណកឈាមក្រៀមៗពេញមុខ និងសក់ និយាយផងយកដៃកេះក្រមរឈាមចេញបណ្ដើរ។

ស្អែកឡើង ខ្ញុំយកការសុបិននេះ



ទិដ្ឋភាពសុបិនៈ ខ្ញុំសុបិនឃើញឪពុកម្ដាយអង្គុយជជែកគ្នាលេងនៅផ្ទះមួយដែលសង់ពីឫស្សីប្រក់ស្លឹកត្នោតនៅខាងលិចទួលស្វាំង។
(ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រាប់ដល់បងស្រីជា ពេលខ្ញុំនិយាយចប់ គាត់មានទឹកមុខរលីងរលោងហើយ និយាយអួលដើមកស្ទើរមិនចេញតបមកខ្ញុំវិញថា "ត្រូវហើយប្អូន ប្អូនដឹងទេ នេះប្រហែលជាយើងបានធ្វើបុណ្យរំឭកខួបនៃការធ្វើឃាដទៅលើរូបគាត់។ ដោយយើងបាននិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត និង ធម្មទេសនាកតញ្ញូកតញ្ញូតា ឧទ្ទិសចំពោះមាតាបិតា បងប្រុស និងប្អូនភ្លោះ។ ការធ្វើបុណ្យទាំងនេះបានទៅដល់ព្រលឹងគាត់ហើយបានជាប្អូនយល់សប្តិឃើញគាត់ទាំងពីរមានភាពសម្បូរសប្បាយ និងកាលពីប៉ុន្មានខែមុនបងក៏បានសុបិនឃើញម៉ែសម្រាន្តលើអង្រឹង ព្រលឹងបងសួរទៅគាត់ថា ម៉ែ! កូនយករបស់ម៉ែទុកឲ្យចែកប្អូនៗ ទៅដូរយកអង្ករតើម៉ែខឹងនឹងកូនឬទេ? ពេលនោះម៉ែងាកមកយកដៃអង្អែលក្បាលបងភ្លាម នោះបងមើលឃើញមុខនឹងខ្លួនប្រាណរបស់គាត់ មានពណ៌ខ្មៅដូចរោលដែងភ្លើង និងសក់កន្ទ្រីងកន្ទ្រើង"។

ពេលនោះបងស្រីហូរទឹកភ្នែកកាន់តែខ្លាំងហើយ ខំប្រឹងនិយាយប្រាប់ខ្ញុំ។ ប្អូនដឹងទេពេលគេយកម្ដាយយើងទៅសម្លាប់នៅលើទួលស្វាំង។ មានអ្នក

ឡើងត្នោតម្នាក់ ជាអ្នកធ្វើស្ករត្នោត ដែលអង្គការចាត់តាំងនៅក្បែរទីនោះ។ ល្ងាចព្រលប់ៗ គាត់បានមើលពីលើចុងត្នោត ឃើញកងឈ្លបពីរនាក់ ម្នាក់ស្ពាយកាំភ្លើង ឯម្នាក់ទៀតកាន់ដែកភ្លៅរទេះ បណ្ដើរម្ដាយយើងចងមុខនឹងក្រណាត់ខ្មៅ ឆ្ពោះទៅអណ្ដូងចាស់មួយក្បែរនោះ។ បន្ទាប់មកអាម្នាក់ដែលស្ពាយកាំភ្លើងបានភ្ជង់បញ្ឈរឲ្យម្ដាយយើងលុតជង្គង់ចុះនៅមាត់អណ្ដូង ប្រាប់ឲ្យគាត់ដាក់ដៃមកក្រោយ បម្រុងចងស្លាបសេកនឹងខ្សែធាងត្នោតដែលវាកាន់នៅនឹងដៃ។ ឯម្នាក់ទៀតឈរពីចំហៀង យារដែកភ្លៅរទេះបម្រុងវាយសម្លាប់ទម្លាក់អណ្ដូង ភ្លាមនោះម្ដាយយើងក៏ស្ទុះឱបទាញជើងអាម្នាក់ស្ពាយកាំភ្លើងដែលបម្រុងចងស្លាបសេក លោតចូលទៅក្នុងអណ្ដូងទាំងពីរនាក់។

រំពេចនោះបងស្រីខ្ញុំហូរទឹកភ្នែកអួលដើមកនិយាយមិនចេញ ចុងក្រោយខំប្រឹងនិយាយបានត្រឹមថា ម្ដាយយើងគេសម្លាប់យ៉ាងវេទនាជាទីបំផុត ដោយពួកកងឈ្លបបានបោកគ្រាប់បែកសម្លាប់ពីលើចូលទៅក្នុងអណ្ដូងជាមួយ កងឈ្លបនោះក៏ស្លាប់ក្នុងអណ្ដូងនោះដែរ។ អ៊ីចឹងបានជាប្អូនសុបិនឃើញមុខ និងសក់គាត់ប្រឡាក់សុទ្ធតែឈាម។ រួចបងស្រីយកក្រមាជូតទឹកភ្នែក ហើយស្ទុះរត់ទៅសម្រាន្តលើអង្រឹងយកក្រមាខ្ទប់មុខយំយ៉ាងខ្សឹកខ្សួល។

ទឹកភ្នែកខ្ញុំចាប់ផ្ដើមហូរស្រោចផែនថ្ពាល់ទាំងមិនដឹងខ្លួន នឹកអាណិតអ្នកម្ដាយពេលនៅមានជីវិតឈ្លុសឈ្លុលខិតខំរិះរកគ្រប់វិធីដើម្បីឲ្យក្រុមគ្រួសាររួចផុតពីការយកទៅសម្លាប់។ មិនតែប៉ុណ្ណោះគេធ្វើទុក្ខបុកម្នេញលើផ្លូវកាយ ធ្វើការធ្ងន់ធ្ងរ និងធ្វើបាបលើផ្លូវចិត្តគ្មានពេលស្រាកស្រាន្តនៃជីវិតរស់នៅក្នុងលំហគុកកម្ពុឥតរនាំង។ ទោះជាយើងគ្មានកំហុស ហើយគេចោទប្រកាន់ឲ្យឆ្លើយសារភាពកំហុសទាំងក្បត់ឆន្ទៈ ក៏យើងឆ្លើយទាំងបំពានដែរដើម្បីរស់ តែទោះជាយ៉ាងណាក៏ដោយជីវិតចុងក្រោយត្រូវគេសម្លាប់យ៉ាងវេទនាជាទីបំផុតទៀត។

ថ្ងៃក្រោយជាបន្តបន្ទាប់ បងស្រីនិងខ្ញុំតែងតែសួរនាំអ្នកដែលធ្លាប់ឡើងត្នោតដែលបានឃើញព្រឹត្តិការណ៍ដ៏រន្ធត់នៃកងឈ្លបសម្លាប់ម្ដាយខ្ញុំ។ ប៉ុន្តែគាត់បានបដិសេធថា "ពុំគេនិយាយតៗគ្នា មិនបានឃើញទេ។" ខ្ញុំដឹងថាគាត់ខ្លាចមានការសងសឹកពីកូនៗដែលនៅរស់ទៅលើរូបគាត់ក្នុងការភាន់ច្រឡំណាមួយ។ នេះជាការគិតខុសស្រឡះ។

កូនៗទាំងអស់ពិតជាមិនមានបំណុលឈាមប្រចាំចិត្តចងគំនុំចំពោះអ្នកទាំងអស់នោះឡើយ ព្រោះបណ្ដាំរបស់ឪពុកខ្ញុំបានផ្ដាំដល់កូនៗ មុនពេលគេយកគាត់ទៅសម្លាប់ថា "បើឪពុកម្ដាយត្រូវគេសម្លាប់ សូមកូនៗកុំធ្វើការសងសឹកនឹងគេអី បើមិនដូច្នេះកម្មពៀរវេរានឹងធ្លាក់មកលើកូនមិនចេះចប់មិនចេះហើយ ព្រោះនេះជាកម្មឪពុកពីជាតិមុន ដូចនេះត្រូវបញ្ចប់ត្រឹមពុកចុះ" កូនត្រូវចាំថា "កម្មពៀរត្រូវបានរំងាប់ដោយការមិនចងពៀរ"។

ប៉ុន្តែខ្ញុំនិងបងស្រីនៅតែទទូចឲ្យអ្នកដែលជិតដិតនឹងអ្នកឡើងត្នោតនោះជួយសួរនាំ ហើយប្រាប់ថាមិនអីទេ កូនៗគ្រាន់តែចង់ដឹងរឿងរ៉ាវប៉ុណ្ណោះ។

---

# សម្រែកកំហឹងប្ដូរឈាម បិសាចខ្មៅក្បួចចប គ្រាប់បែកដៃពិឃាដ

ក្ដីទន្ទឹងការចង់ដឹង ពិតជាធ្វើឲ្យខ្ញុំនិងបងស្រីអន្ទះសា នៅមិនសុខក្នុងចិត្ត។ យូរខែកន្លងថ្ងៃមួយយប់មួយ ខ្ញុំនិងបងស្រីបានដឹងរឿងនោះច្បាស់មិនអាចបំភ្លេចបាន តាមរយៈសម្ដីចម្លងរបស់ពូអិដែលបានសួរនាំពីអ្នកឡើងត្នោតនោះ។

បន្ទាប់ពីកងឈ្លបនោះឲ្យម្ដាយខ្ញុំលុតជង្គង់នៅមាត់អណ្ដូងចាស់មួយ កងឈ្លបនោះបានសម្លុតភ្ជង់នឹងកាំភ្លើងស្រែកដាក់ឲ្យដាក់ដៃទាំងពីរទៅក្រោយដើម្បីចងស្លាបសេក និងមានក្រណាត់ខ្មៅចងមុខផង។ រំពេចនោះម្ដាយខ្ញុំបានស្ទុះឱបជើងកងឈ្លបម្នាក់ដែលរៀបនឹងចងនោះ លោតចូលទៅក្នុងអណ្ដូងទាំងអស់គ្នា។ អាម្នាក់ដែលកាន់ដែកភ្លៅរទេះវង់ចាំវាយសម្លាប់ពីក្រោយពេលឃើញដូច្នោះ ឆ្ងៃឆ្ងាស្ងន់ស្ងោ ហើយរត់ទៅរោងយាមក្បែរនោះ ប្រាប់មេកងឈ្លបគេថា "សមមិត្តៗ ស្ត្រីម្នាក់ដែលបណ្ដើរយកទៅសម្លាប់អម្បាញ់មិញ បានទាញគ្នាយើងម្នាក់ចូលទៅក្នុងអណ្ដូង និងកាំភ្លើងមួយដើមផង"។

មេកងឈ្លបនោះប្រញាប់ប្រញាល់រត់មកវិញទាំងពីរនាក់យ៉ាងលឿន ហើយអើតមើលទៅក្នុងអណ្តូង មិនបង្អង់យូរ មេកងឈ្លបនោះបានទាញគ្រាប់បែកមួយគ្រាប់ពីចង្កេះ បោះចូលទៅក្នុងអណ្តូង ហើយពួកគេថយពីរបីជំហានក្រាបផ្ងាល់នឹងដី ឮសំឡេងផ្ទុះខ្ទរពេញទួល បន្ទាប់មកផ្សែងហុយទ្រលោមឡើងទៅលើ លាយនឹងសំឡេងស្រែកមនុស្សស្រីចេញពីអណ្តូងមកថា "ម៉ែអើយជួយកូនផង!" មិនបង្អង់យូរ វាក៏ទាញមួយគ្រាប់ទៀតពីចង្កេះ បោះចូលទៅក្នុងអណ្តូងនោះ។ សម្រែកស្រែកក៏ស្ងាត់ភ្លាមមួយរំពេច។ មានតែផ្សែងនៅហុយទ្រលោមចេញមក បញ្ជាក់ថាគាត់បានដាច់ខ្យល់ស្លាប់ហើយជាមួយនឹងគ្រាប់បែកដៃទីពីរ។

អ្នកឡើងត្នោតនោះលាន់មាត់ថា គិតទៅពួកនោះ សូម្បីតែគ្នាវាក៏ពួកវាសម្លាប់ដែរ។ គឺពិតជាសាហាវមែន។ អ្នកឡើងត្នោតនោះឃើញទិដ្ឋភាពដូចនេះមានអារម្មណ៍ភ័យខ្លាចស្ទើរតែកាន់ធាងត្នោតមិនជាប់ដៃញ័រមិនហ៊ានចុះមកក្រោមភ្លាមទេ នៅសំងំលើចុងត្នោតរហូតស្ងប់ស្ងាត់ទើបហ៊ានចុះមកមិនឲ្យឮសម្រឹបជើងរហូតដើរដល់ផ្ទះ ដោយលាក់ទុករឿងនេះក្នុងចិត្តជារៀងរហូត។

បន្ទាប់មកពួកកងឈ្លបបានបណ្តើរអ្នកទោសផ្សេងៗទៀតមកវាយសម្លាប់ទម្លាក់ក្នុងអណ្តូងនោះម្តងមួយៗ មានទាំងស្ត្រីមានផ្ទៃពោះគ្រប់ខែទៀតផង រហូតដល់ពេញអណ្តូង ពួកកងឈ្លបចាប់ផ្តើមកាយដីលុបអណ្តូងទាំងអ្នកខ្លះនៅសល់ដង្ហើមមិនទាន់ស្លាប់។ បន្តមកទៀតពួកវាយកធាងត្នោតងាប់ៗ និងខោអាវចាស់ៗមកដុតពីលើដើម្បីបំបិទដាន និងជះក្លិនឆ្អេះ



ទិដ្ឋភាពតំណាងៈ កងឈ្លបបញ្ជាឲ្យម្តាយខ្ញុំដាក់ដៃទៅក្រោយបម្រុងចងស្លាបសេក ដើម្បីវាយទម្លាក់ចូលអណ្តូង។ (ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទិដ្ឋភាពតំណាងៈ ម្តាយខ្ញុំទាញកងឈ្លបម្នាក់ដែលបម្រុងចងស្លាបសេកចូលនៅក្នុងអណ្តូងទាំងអស់គ្នា។ (ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទិដ្ឋភាពតំណាងៈ មេកងឈ្លបបោះគ្រាប់បែកចូលទៅក្នុងអណ្តូងដើម្បីសម្លាប់ម្តាយខ្ញុំរួមនឹងកងឈ្លបម្នាក់ទៀត។ (ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្អាបឈ្ងៀមពេញទួល ហើយពួកវាចាប់ផ្តើមបន្តទៅរណ្តៅផ្សេងទៀត។

ក្នុងមួយយប់ៗ ពួកកម្មាភិបាលខ្មែរក្រហមសម្លាប់គ្រួសារប្រជាជនថ្មីបានច្រើន ឬតិចទៅតាមថ្ងៃដែលអង្គការប្រមូលបានពីភូមិផ្សេងដោយដឹកតាមរទេះគោ រទេះសេះ និងធ្វើដំណើរដោយថ្មើរជើង ដែលគេប្រាប់ថាឲ្យមករស់នៅលើទួលស្វាំងនេះ គិតទាំងមនុស្សចាស់ ក្មេង កូនង៉ែត ស្ត្រីមានផ្ទៃពោះ មានខ្សែស្រឡាយ

**ឡុង វង្សសមិទ្ធ**

***(តនៅលេខក្រោយ)***

រូបក្របមុខ៖
កែវ ណាន អាយុ៩៥ឆ្នាំ នៅវត្តលង្កា។
( អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

រូបក្របក្រោយ៖
លោក ឆាំង យុ កូនប្រុសពៅ កែវ ណាន បួសនៅថ្ងៃដែលម្តាយទទួលមរណភាព នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣។
( អ៊ូច មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា )




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 284, August 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.